ឧបសម្ព័ន្ធ ១

# របាយការណ៍បូកសរុប
# ប្រចាំឆ្នាំ២០២០











## អង្គការកែប្រែសហគមន៍

#០៩៩ ក្រុមទី១ ភូមិថ្នល់ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប

Facebookpage: CTO Cambodia-អង្គការកែប្រែសហគមន៍ Website: [www.ctocambodia.org](http://www.ctocambodia.org)

**ប្រភពមូលនិធិ:**

មាតិការ

I. អំពីអង្គការកែប្រែសហគមន៍

II. ពត៏មានគម្រោង

III. ពិពណ៏នាការរីកចម្រើនរបស់គម្រោង (ឧបសគ្គរាំងស្ទះនិងមេរៀន)

IV. របាយការណ៍ហិរញ្ញវត្ថុ

V. ផែនការទិសដៅការងារបន្ត

## I. **អំពីអង្គការកែប្រែសហគមន៍**

អង្គការកែប្រែសហគមន៍ Community Translation Organization, អក្សរកាត់ (CTO) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយ ដែលត្រូវបានចុះបញ្ជីរនៅក្រសួងមហាផ្ទៃនៃព្រះរាជាណាចក្រកម្ពុជា លេខ ១៤៩៣ សជណ ថ្ងៃទី៣០ ខែ មិនថុនា ឆ្នាំ ២០០៩។ ស្នាក់ការកណ្តាលរបស់អង្គការមានទីតាំងស្ថិតនៅ ផ្ទះលេខ ០៩៩ ផ្លូវជាតិលេខ៦ ភូមិថ្នល់ សង្កាត់ស្រង៉ែ ក្រុងសៀមរាប ខេត្តសៀមរាប និងស្នាក់ការសាខាទីតាំងស្ថិតនៅ ភូមិអូរក្រវ៉ាន់ សង្កាត់សំរោង ក្រុង សំរោង ខេត្តឧត្តរមានជ័យ។ ដែលជាទីតាំងយុទ្ធសាស្រ្តមួយដើម្បីសម្របសម្រួលប្រតិបត្តិការណ៍ ការងារចូលរួមកិច្ចការ ងារអភិវឌ្ឍន៍ សម្រាប់បណ្តាខេត្តភូមិភាគពាយ័ព្យនៃប្រទេសកម្ពុជាដូចជាខេត្តសៀមរាប ព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង និងកំពង់ធំ។

អង្គការកែប្រែសហគមន៍ ធ្វើការងារដើម្បីកសាងមូលដ្ឋានគ្រឹះ ដល់សហគមន៍ដែលអាស្រ័យផលនឹងរបរកសិកម្ម ដោយផ្តោតលើវិស័យកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ ការកសាងសមត្ថភាពក្រុមអង្គការកសិករ ដែលមានដូចជា ក្រុមសន្សំប្រាក់ សហគមន៍កសិកម្ម សហគមន៍ព្រៃឈើ សហគមន៍ទេសចរធម្មជាតិ សហគមន៍ស្រះជម្រកត្រីមេពូជ ជម្រុញការអភិវឌ្ឍន៍តាមបែបប្រជាធិបតេយ្យ ការអប់រំកុមារនៅកម្រិតថ្នាក់មូលដ្ឋាន ការលើកំពស់សមភាពយែនឌ័រ សហគ្រិនភាពនារី ការអប់រំផ្សព្វផ្សាយដល់សហគមន៍ លើបញ្ហាបម្រែបម្រួល និងការបន្សាំនឹងការប្រែប្រួលអាកាសធាតុ ការកាត់បន្ថយគ្រោះភ័យធម្មជាតិ ដើម្បីឆ្ពោះទៅរកការកសាងសមត្ថភាពសហគមន៍ ដែលអាចធន់ទ្រាំទៅនឹងបញ្ហា សង្គម និងសេដ្ឋកិច្ច។

អង្គការកែប្រែសហគមន៍ គឺជាផ្នែកមួយនៃកម្មវិធីរបស់អង្គការ Human Translation ដែលជាអង្គការក្រៅរដ្ឋាភិបាលអន្តរ ជាតិមួយមានមូលដ្ឋាននៅសហរដ្ឋអាមេរិក (គេហទំព័រwww.humantranslation.org)។ ក្នុងឆ្នាំ២០០៩ តាមរយៈការធ្វើកំនែទម្រង់ អង្គការកែប្រែសហគមន៍ បានប្រែក្លាយមកជាអង្គការមិនមែនរដ្ឋាភិបាលឯករាជ្យក្នុងស្រុកមួយ ដែលបានចុះបញ្ជីទទួលស្គាល់ស្របច្បាប់ជាមួយរាជរដ្ឋាភិបាលកម្ពុជា នៅក្រសួងមហាផ្ទៃ។

- <u>បាវចនា</u> ៖ ប្រែក្លាយចំណេះដឹងទៅជាសកម្មភាពអភិវឌ្ឍន៍។
- <u>ទស្សនវិស័យ</u> ៖ ប្រជាជនអាចធ្វើកិច្ចការដើម្បីកែលំអរជីវភាព និងសេដ្ឋកិច្ចបានប្រសើរឡើង នៅពេល ដែលពួកគាត់ទទួលបាននូវសម្ភារៈ ចំណេះដឹង ជំនាញ និងធនធានសមស្រប។
- <u>បេសកកម្ម</u> ៖ ចូលរួមជាមួយសហគមន៍ ក្នុងការកាត់បន្ថយភាពក្រីក្រ អភិវឌ្ឍសេដ្ឋកិច្ច តាមរយៈ ពង្រឹងភាពអង់អាចរបស់សហគមន៍ ការគាំទ្រហេដ្ឋារចនាសម្ព័ន្ធរូបវន្តកសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ អេកូទេសចរណ៍ និងធ្វើអោយប្រសើរឡើងនូវការចិញ្ចឹមជីវិតដោយភាពថ្លៃថ្នូរ និងមានការការគោរពសិទ្ធិ សេរីភាពពេញលេញ។

**<u>ក្រុមប្រឹក្សាភិបាលរបស់អង្គការ</u>**

| ឈ្មោះ | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន |
|---|---|---|
| Kat Bun Heng | ស្ថាបនិក<br>ប្រធានក្រុមប្រឹក្សាភិបាល | សាលាកំរើក ក្រុងសៀមរាប<br>E-mail: kat.bunheng@gmail.com |
| Tobias Rose-Stockwell | ស្ថាបនិក<br>សមាជិកក្រុមប្រឹក្សាភិបាល | California, USA<br>E-mail: tobias@humantranslaionn.org |
| Jon Morgan | សមាជិកក្រុមប្រឹក្សាភិបាល /ប្រធាន<br>LAKECLINIC.org | ស្វាយដង្គុំ ក្រុងសៀមរាប<br>E-mail: jmorgan@lakeclinic.org |
| Kristen Davies | សមាជិកក្រុមប្រឹក្សាភិបាល<br>ទីប្រឹក្សា GIZ ប្រចាំសៀមរាប | សាលាកំរើក ក្រុងសៀមរាប<br>E-mail : kdavies025@gmail.com |

**<u>បុគ្គលិកលេខាធិការដ្ឋាន</u>**

| ល.រ | នាម និងគោត្តនាម | ឋានៈ និង ស្ថាប័ន | អាស័យដ្ឋាន | ទំនាក់ទំនង |
|---|---|---|---|---|
| ១ | លោក យិញ យ៉ា | នាយកប្រត្តិបត្តិ(ពេញម៉ោង) | សៀមរាប | ០១២៧០៧៤៧៤ |

| | | | | |
|---|---|---|---|---|
| ២ | លោកស្រី សៀង សុធារី | ប្រធានគ្រប់គ្រងហិរញ្ញវត្ថុ(ពេញម៉ោង) | សៀមរាប | ០១២៤៥១៨៧៧ |
| ៣ | លោក ថៃ ពិសី | ប្រធានកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៦២២១៨១ |
| ៤ | លោក ម៉យ រ៉ាមន | មន្ត្រីកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៧២៨១៩២ |
| ៥ | លោក សួន វាសនា | មន្ត្រីកម្មវិធី(ពេញម៉ោង) | សៀមរាប | ០៩២៥៥៣០១៣ |
| ៦ | លោក រិត បូ | ប្រធានសម្របសម្រួលខេត្ត(ពេញម៉ោង) | ឧត្តមានជ័យ | ០១២៣៥១៦៩៦ |
| ៧ | លោកស្រី ទេព សាម៉េត | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩២៥០២៦២០ |
| ៨ | កញ្ញា ខា គឹមយួយ | មន្ត្រីជំនួយការកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៩៣២៤០១០១០ |
| ៩ | លោកស្រី យ៉ាន់ ម៉ូវជី | មន្ត្រីរដ្ឋបាល និងហិរញ្ញវត្ថុ(ពេញម៉ោង) | ឧត្តមានជ័យ | ០១២៣១៧៩៩៧ |
| ១០ | កញ្ញា សួន សោភា | មន្ត្រីកម្មវិធី(ពេញម៉ោង) | ឧត្តមានជ័យ | ០៨៨៩៩១៤០៥០ |
| ១១ | កញ្ញា ទីវ សាវ័ន្ត | ជំនួយការរដ្ឋបាល(ពេញម៉ោង) | សៀមរាប | ០៩៩៧០១៣៧៣ |
| ១២ | Ms. Caroline Le Roy | អ្នកស្ម័គ្រចិត្ត | បារាំង | leroy.caroline29@gmail.com |
| ១៣ | Ms. Calypso Demoustier | អ្នកស្ម័គ្រចិត្ត | បារាំង | Calypso-nl@hotmail.fr |
| ១៤ | Mr. Quentin Arnould | អ្នកស្ម័គ្រចិត្ត | បារាំង | Quentinarnould1995@gmail.com |
| ១៥ | Ms.Anaïs Moindron | អ្នកស្ម័គ្រចិត្ត | បារាំង | anais.moindron@yahoo.fr |

**វិស័យផ្តោតការយកចិត្តទុកដាក់**

| ប្រភេទនៃកម្មវិធី/គម្រោង/សកម្មភាព | ទីកន្លែង | រយៈពេល | ដៃគូគម្រោង | ប្រភពថវិកា / យន្តិជ | ស្ថានភាព/បញ្ចប់/កំពង់បន្ត |
|---|---|---|---|---|---|
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន អភិបាលកិច្ច អប់រំនិងយែនឌ័រ | សៀមរាប | ៣ឆ្នាំ | -ក្រុមប្រឹក្សឃុំ<br>-ការិយាល័យអប់រំស្រុក | Actionaid | បញ្ចប់ ០១មេសា២០១៦ |
| និយ័តកម្មព្រៃឈើ ទឹកស្អាតនិងអនាម័យ | ព្រះវិហារ | ៣ ឆ្នាំ | -សហគមន៍ព្រៃឈើ<br>-រដ្ឋបាលព្រៃឈើ<br>-មន្ទីរអភិវឌ្ឍន៍ជនបទ | OXFAM GB | បញ្ចប់ ០៨សីហា២០១៥ |
| អេកូទេសចរណ៍ គ្រប់គ្រងធនធានធម្មជាតិបំរែបំរួលអាកាស ធាតុការចិញ្ចឹមជីវិត | សៀមរាប | ២ ឆ្នាំ | ក្រុមប្រឹក្សឃុំ | UNDP SGP | បញ្ចប់ ៣០ធ្នូ២០១៣ |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៨ឆ្នាំ | សហគមអភិវឌ្ឍកសិកម្ម | SIDA/ WEFFECT | បញ្ចប់ (កក្កដា២០២០) |
| សេដ្ឋកិច្ចកសិកម្ម និងទីផ្សារ | សៀមរាប | ៥ ឆ្នាំ | មន្ទីរកសិកម្ម | AusAID | បញ្ចប់ ០៦កក្កដា២០១៤ |
| សន្តិសុខស្បៀង ពង្រឹងសិទ្ធមូលដ្ឋាន អភិបាលកិច្ច អប់រំ និងយែនឌ័រ គ្រប់ គ្រង់គ្រោះមហន្តរាយ | ឧត្តរមានជ័យ | ៨ឆ្នាំ | -បណ្តាញសហគន៍ព្រៃឈើ<br>-បណ្តាញគាំទ្រសហគមន៍ | Actionaid | បន្ត |
| គ្រប់គ្រងធនធានធម្មជាតិបំរែបំរួលអាកាសធាតុការចិញ្ចឹមជីវិត | សៀមរាប | ១.៨ ឆ្នាំ | ក្រុមប្រឹក្សឃុំ<br>ឧទ្យានជាតិ<br>រដ្ឋបាលស្រុក | UNDP SGP | បញ្ចប់ ២០១៨ |
| កសិកម្ម និងការចិញ្ចឹមជីវិត | សៀមរាប | ១ឆ្នាំ | សហគមន៍កសិកម្ម | DAP/DIFAT | បញ្ចប់ ២០១៨ |
| ជម្រុញសហគ្រិនវ័យក្មេង | សៀមរាប | ២ឆ្នាំ | ពាណិជ្ជកម្ម | PACT/WE Act | បន្ត |

## II. ព័ត៌មានគម្រោង

១.ខេត្តសៀមរាប មាន២គម្រោងដែលប្រភពថវិកាមកពីម្ចាស់ជំនួយ WeEffect, PACT/USAID

គម្រោងទី១

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងជម្រុញសហគ្រិនស្ត្រីវ័យក្មេង(WE Act) |
| គោលដៅរួម | សម្របសម្រួល ជម្រុញក្រុមស្ត្រីវ័យក្មេងឲ្យទទួលបានវគ្គបណ្តុះបណ្តាលតាមជំនាញដែលពួកគេត្រូវការ និងកំពុងអនុវត្តដើម្បីមានចំណេះ ជំនាញពិតប្រាកដ |
| តំបន់គោលដៅ | -ខេត្ត: សៀមរាប<br>-ក្រុង សៀមរាប |
| ក្រុមគោលដៅ | (១)-អាជីវករជាស្ត្រីដែលមានមុខរបរស្រាប់ និងកំពុងរៀបចំបើកអាជីវកម្មផ្ទាល់ខ្លួនចំនួន២៥០នាក់ |
| អ្នកទទួលផលផ្ទាល់ | ២៥០គ្រួសារ |
| អ្នកទទួលផលប្រយោល | ១៥៧៥នាក់ ស្រី៨៥៥នាក់ |

គម្រោងទី២

| | |
|---|---|
| ឈ្មោះគម្រោង | គម្រោងបង្កើនសមត្ថភាពផ្នែកសង្គម និងសេដ្ឋកិច្ច របស់អង្គការកសិករ ដោយមានការចូលរួមដ៏មានអត្ថន័យពីស្ត្រី នៅខេត្តសៀមរាប ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ |
| គោលដៅរួម | ចូលរួមកាត់បន្ថយភាពក្រីក្រប្រជាពលរដ្ឋតាមរយៈការពង្រឹងសេដ្ឋកិច្ចកសិករនិងសមត្ថភាពអង្គការសហគមន៍ |
| តំបន់គោលដៅ | -ខេត្ត: សៀមរាប<br>-ស្រុក: ពួក ស្រុកបន្ទាយស្រី ស្រុកប្រាសាទបាគង ស្រុកសូត្រនិគមន៍<br>-ឃុំ: កែវពណ៌ សំរោងយា ពួក ត្បែង ខ្នាស់ ត្រពាំងធំ |
| ក្រុមគោលដៅ | សហគមន៍កសិកម្ម ១២ ក្រុមសន្សំ២៥ក្រុម សហភាពសហគមន៍កសិកម្ម១ ក្រុមយុវជន៣ក្រុម |
| អ្នកទទួលផលផ្ទាល់ | ១៤៨៦គ្រួសារ |
| អ្នកទទួលផលប្រយោល | ៣០០០នាក់ ស្ត្រី ១៥៨៨នាក់ |

២.ខេត្តឧត្តរមានជ័យ មានគម្រោងមេ១ដែលប្រភពថវិកាមកពី Actionaid

| | |
|---|---|
| ឈ្មោះគម្រោង | កម្មវិធីសិទ្ធិមូលដ្ឋាន (LRP) |
| គោលដៅរួម | កសិករ និងកុមារក្រីក្រនៅក្នុងតំបន់គោលដៅរបស់គម្រោង នឹងទទួលបាននូវសន្តិសុខស្បៀង និងឱកាសទទួលបានការសិក្សាប្រសើរជាងមុន ដោយពួកគេមានលទ្ធភាព ទទួលបាននូវសិទ្ធិជាមូលដ្ឋាន ហើយអនុវត្តសិទ្ធិទាំងនោះតាមផ្លូវច្បាប់ ដើម្បីរស់នៅប្រកបដោយភាពថ្លៃថ្នូរនៅក្នុងសង្គម។ |
| តំបន់គោលដៅ | -ខេត្ត: ឧត្តរមានជ័យ<br>-ស្រុក: សំរោង បន្ទាយអំពិល ចុងកាល់ អន្លង់វែង<br>-ឃុំ: សំរោង បន្សាយរាក់ កូនក្រៀល គោកខ្ពស់ ពង្រ លំទង |
| ក្រុមគោលដៅ | សហគមន៍ព្រៃឈើ ៤ ក្រុមសន្សំ៨ក្រុម បណ្តាញសហគមន៍ព្រៃឈើខេត្ត១ ក្រុមជង្រុកស្រូវ ៨ សាលាបឋមសិក្សា២០ |
| អ្នកទទួលផលផ្ទាល់ | ១៨៦៣គ្រួសារ |
| អ្នកទទួលផលប្រយោល | ៩៣៣៨នាក់ ស្រី៤៧៥០នាក់ ក្នុងនោះកុមារសរុប៣២៦៨នាក់ |

**ពិពណ៌នាការរីកចម្រើនរបស់គម្រោង**

**១.ខេត្តសៀមរាប**

*គម្រោងទី១*

អង្គការកែប្រែសហគមន៍បានចុះកិច្ចព្រមព្រៀងជាមួយអង្គការPactដើម្បីអនុវត្តjតគម្រោងកម្មវិធីសហគ្រិននារីសេកម្ម WE Act ក្នុងខែវិច្ឆិការឆ្នាំ២០១៩

ដែលគម្រោងសាកល្បងនេះមានរយះពេលមួយឆ្នាំ។ ជាមួយនឹងការ គាំទ្រមូលនិធិសម្រាប់គម្រោងសហគ្រិននារីសកម្មនេះ អង្គការកែប្រែសហគមន៍ធ្វើការលើការកសាងលើជំនាញរឹងនិងទន់ដល់យុវតី និងសហគ្រិននារីវ័យក្មេងក្នុងប្រជុំជនក្រុងសៀមរាប ដោយមានការផ្តល់ជូនជាវគ្គ បណ្តុះបណ្តាលជាខ្សែរតាមលំដាប់លំដោយទៅដល់ពួកគាត់ ក៏ដូចជាការជម្រុញចិត្តពួកគាត់លើការធ្វើអាជីវកម្មជាបណ្តាញ និងចែករំលែកចំនេះដឹងបទពិសោធន៍គ្នារវាងក្រុមពួកគាត់  ជាមួយនឹងដៃគូរពាក់ព័ន្ធផ្សេងទៀតក្នុងខេត្តសៀមរាប។  ដោយមានការសហការណ៍ជាមួយសាកលវិទ្យាល័យសៅអ៊ីសអេស៊ា USEA អង្គការCTOបានចលនាបង្កើតបណ្តាញសហគ្រិននារីវ័យក្មេងមួយដើម្បីអោយសហគ្រិនវ័យក្មេងក៏ដូចជាយុវជនក្នុងគម្រោងអាចជួបជុំគ្នាធ្វើការផ្លាស់ប្តូរព័ត៌មាន ចំណេះដឹង បទពិសោធន៍ ក៏ដូចជាបញ្ហាប្រឈមនានាជុំវិញការធ្វើអាជីវកម្មរបស់ខ្លួន ហើយនឹងជាវេទិកាក្នុងការភ្ជាប់ទំនាក់ទំនងធុរកិច្ចផងដែរ។  នៅត្រីមាសទី១  អង្គការCTOបានធ្វើការចុះសិក្សារកំណត់យុវតី  និងសហគ្រិននារីដែលមានសក្តានុពលចាប់អារម្មណ៍ចូលរួមជាក្រុមគោលដៅគម្រោងតាមតំបន់គោលដៅនៃខេត្តសៀមរាប។ ហើយទន្ទឹមនឹងនោះ យើងក៏បានធ្វើការផ្សព្វផ្សាយផែនការគម្រោង ទៅដល់សហគមន៍អ្នកពាក់ព័ន្ធតាមមូលដ្ឋាន  អោយបានដឹងស្គាល់ពីគម្រោងផែនការដែលយើងលមាន។ បន្ទាប់ពីកំណើតជ្រើសរើសអ្នកទទួលផលតាមគោលដៅគម្រោងរួចហើយយើងបានរៀបចំចងក្រងព័ត៌មាន ពួកគាត់ដើម្បីបញ្ចូលឈ្មោះពួកគាត់ជាក្រុមគោលដៅគម្រោង ក្នុងបញ្ជីទិន្នន័យគម្រោងជាផ្លូវការ។ រួចហើយយើងក៏បានធ្វើការសិក្សារពីតម្រូវការពួកគាត់ ដោយការស្រង់ព័ត៌មានតម្រូវការពីអ្នកទទួលផលចំនួន៩០នាក់ មានសហគ្រិននារីនិងយុវជនដើម្បីរកអោយឃើញពីតម្រូវការអទិភាពរបស់ពួកគាត់ភាគច្រើន ដែលចង់បានអោយគម្រោងដោះស្រាយឆ្លើយតបទៅពួកគាត់តាមរយះគម្រោងនេះ។ ក្រោយធ្វើការសិក្សាតម្រូវការយើងរកឃើញថាពួកគាត់ចង់បានវគ្គបណ្តាលទៅលើជំនាញសំខាន់៥៖1)មូលដ្ឋានគ្រឹះក្នុងការធ្វើអាជីវកម្ម 2)ការកសាងផែនការអាជីវកម្ម 3) ការធ្វើទីផ្សារ 4)សហគ្រិនភាព 5) បច្ចេកវិទ្យាព័ត៌មានសម្រាប់អាជីវកម្ម ជាមួយគ្នានេះផងដែរអង្គការCTO បានរៀបចំកិច្ចប្រជុំជាមួយអ្នកពាក់ព័ន្ធមានដូចជាមន្ទីរកិច្ចការនារី មន្ទីរពាណិជ្ជកម្ម មន្ទីរសិប្បកម្ម នវានុវត្តន៍ មន្ទីរការងារ បណ្តុះបណ្តាលវិជ្ជាជីវះ ដើម្បីបង្ហាញពីផែនការគម្រោងក៏ដូចជាការស្វែងរកកិច្ចសហការគាំទ្រដល់សហគ្រិននារីក្នុងគម្រោងផងដែរ។ នៅត្រីមាសទី២ យើងបានធ្វើការកំណត់នូវប្រធានបទសម្រាប់រៀបចំវគ្គបណ្តុះបណ្តាល រៀបចំមេរៀន កិច្ចតែងការមេរៀនដែលត្រូវរៀបចំឡើងមាន២ផ្នែកៈ ទី១សម្រាប់កម្មវិធីពន្លកអាជីវកម្ម និងទី២សម្រាប់កម្មវិធីពន្លឿនអាជីវកម្ម ដែលកម្មវិធីនីមួយៗមាន៥វគ្គ ហើយក្នុង១វគ្គស្មើ១ថ្ងៃ សម្រាប់សិក្ខាកាមចូលរួមចន្លោះពី ៣៥ដល់៥០នាក់ ក្នុង១វគ្គ។ ដើម្បីពង្រឹងការទំនាក់ទំនងរវាងក្រុមគោលដៅគម្រោងជា  ពិសេសក្នុងកំឡុងពេលមានការលំបាក  ដោយសារការរិតត្បិតការជួបជុំព្រោះវិបត្តិកូវីត១៩  យើងបានបង្កើតនូវយន្តការទំនាក់ទំនងតាមបណ្តាញសង្គមដូចជា facebok messenger, WhasApp, Telegram, Skype, Zoom ដើម្បីរក្សាទំនាក់ទំនងក្នុងកំឡុងពេលមានការហាមឃាត់ការជួបជុំមនុស្សច្រើន។ ជាមួយគ្នាហ្នឹងផងដែរបុគ្គលិកគម្រោងបានចុះធ្វើការតាមដាននិងបង្វឹកដល់សហគ្រិននារីគោលដៅចំនួន១១៥នាក់ ដើម្បីតាមដានពីសុខទុក្ខនិងស្ថានភាពជំនួញក្នុងកំឡុងពេលមានវិបត្តិកូវីត១៩នេះ។ គម្រោងក៏បានសម្របសម្រួលរៀបចំការប្រជុំដៃគូរជំនួញរបស់សហគ្រិនបាន៥លើក  និងប្រជុំគណះកម្មការដឹកនាំបណ្តាញសហគ្រិននារីវ័យក្មេងបានចំនួន១៥លើក។  បន្ទាប់មករៀបចំកម្មវិធីប្រកួតប្រជែងជ្រើសរើសសហគ្រិននារីវ័យក្មេងឆ្នើមមួយលើក  ជ្រើសបានសហគ្រិននារីវ័យក្មេងឆ្នើម៥រូប។ ហើយក៏បានសម្របសម្រួលទស្សនកិច្ចសិក្សាជូនដល់សហគ្រិននារីវ័យក្មេង២លើក ទៅកាន់ខេត្តបាត់ដំបង និងខេត្តឧត្តរមានជ័យ ដែលមានអ្នកចូលរួមសរុប៣២រូប និងមានការរៀបចំវេទិកាផ្លាស់ប្តូរបទពិសោធន៍និងឆ្លោះបញ្ជាំងពីសហគ្រិននារីវ័យក្មេងចំនួន២លើកដែលមានអ្នកចូលរួមសរុប ១៣៥នាក់ ទៅលើប្រធានបទសំខាន់ៗ៖

- បង្កើនភាពស្និទ្ធស្នាលរវាងសមាជិកជាមួយគណះកម្មការបណ្តាញសហគ្រិននារីវ័យក្មេង
- បង្ហាញពីគោលដៅ ទស្សនវិស័យ បេសកកម្មនិងគុណតម្លៃ ក៏ដូចជាផែនការយុទ្ធសាស្រ្តរបស់សហគ្រិននារីជាសមាជិក
- ធ្វើការប្រមូលព័ត៌មានត្រឡប់ បញ្ហាប្រឈម និងតម្រូវការសមាជិកក្នុងពេលជួបវិបត្តកូវីត១៩
- ចែករំលែកព័ត៌មាន ចំណេះដឹង បតពីសោធន៍ និងការពិគ្រោះយោបល់ផ្សេងៗ
- បង្ហាញលទ្ធផលការងារគម្រោងប្រចាំឆ្នាំដល់ក្រុមគោលដៅគម្រោងនិងទិសដៅទៅខាងមុខ
- បង្ហាញលទ្ធផលការងារបណ្តាញសហគ្រិននារីវ័យក្មេងប្រចាំឆ្នាំដល់ក្រុមគោលដៅគម្រោងនិងទិសដៅទៅខាងមុខ
- ចែករំលែកចំណេះដឹងលើសេវាកម្មឌីជីថលរបស់ធនាគារ ACLEDA bank និង ABA bank
- ចែកវិញ្ញាប័នបត្របញ្ចប់វគ្គបណ្តុះបណ្តាលដល់សិក្ខាកាម

*<u>គម្រោងទី១</u>*

**<u>វិភាគលទ្ធផល</u>**

ក្នុងកំឡុងឆ្នាំ២០២០នេះ អង្គការកែប្រែសហគមន៍ សម្រេចបាននូវលទ្ធផលសំខាន់ៗ យោងទៅលើគោលបំណង ដែលបានព្រមព្រៀងក្នុងផែនការគម្រោង។ ផ្អែកទៅលើកត្តាភូមិសាស្រ្ត និងប្រជាសាស្រ្ត អង្គការកែប្រែសហគមន៍ធ្វើការនៅតាមបណ្តាខេត្តចំនួន៣គឺខេត្តសៀមរាប ព្រះវិហារ និងឧត្តរមានជ័យ។ ធ្វើការជាមួយសហគមន៍កសិកម្មចំនួន២២ សហភាពសហគមន៍កសិកម្ម១ ដែលមានសមាជិកសរុប២១៥៩នាក់ ហើយ៦០%ជា

ស្ត្រី ដែលឋិតក្នុងឃុំ២១ ស្រុក៨ នៃខេត្តទាំង៣ខាងលើ។ តាមការសង្កេតជារួម ការអនុវត្តសកម្មភាពគម្រោងបានសម្រេចទៅតាមលំដាប់លំដោយនៃផែនការ ដោយគ្មានការផ្លាស់ប្តូរអ្វីជាដុំកំភួនឡើយ នៅក្នុងកម្រិតគោលដៅ លទ្ធផលរយះពេលវែង និងខ្លី។ យ៉ាងណាក៏ដោយ ក៏មានការបត់បែនផ្លាស់ប្តូរតិចតួចទៅលើសកម្មភាពមួយចំនួន ប៉ុន្តែអង្គការកែប្រែសហគមន៍តែងតែឆ្លងការឯកភាពអនុម័តពី វីអេហ្វិកជាមុនសម្រាប់ការស្នើរះរើផ្លាស់ប្តូរសកម្មភាពទាំងនេះ នៅក្នុងកំឡុងពេលនៃការធ្វើការកែសម្រួលខ្ទង់ថវិកាប្រចាំឆ្នាំ។ លទ្ធផលកំឡុងឆ្នាំ២០២០នេះរួមមាន ការបន្តជំនួញស្រូវអង្ករ របស់សហភាពសហគមន៍កសិកម្ម ដែលកំពុងដំណើរការជាជំហានចាប់តាំងពីខែតុលាឆ្នាំ២០១៨។ សហភាពសហគមន៍កសិកម្មសៀមរាបអង្គរ រួមគ្នាបង្កើតឡើងដោយសហគមន៍កសិកម្មចំនួន១០ក្នុងខេត្តសៀមរាប។ ដែលជំនួញចាប់ផ្តើមដំបូងជាមួយនឹងដើមទុនចំនួន១៨លានរៀល ដោយធ្វើការទិញវត្ថុធាតុដើមជាស្រូវពីសមាជិកចំនួន១៥តោនដើម្បីកិនវេចខ្ចប់ជាអង្ករសម្រប់លក់ចេញ។ ម្យ៉ាងវិញទៀត សហភាពសហគមន៍កសិកម្មរំពឹងថានឹងផលិតជាអង្ករបានចំនួន៦៧៥២គក្រ។ តាមការព្យាករណ៍នូវប្រាក់ចំនួលពីជំនួញនេះក្នុងរយះពេល៥ខែគឺអាចនឹងរកបាន ១១៥ ៥៤៦ ៥០០ រៀល។ កសិកដ្ឋានគម្រូ៧ក្នុងចំនោម៩ កំពុងដំណើរល្អប្រសើរ ហើយបានដើរតួនាទីក្នុងការបង្ហាញជូននូវបច្ចេកទេសក្នុងការដាំដុះទៅដល់កសិករដែលរស់នៅជុំវិញ។ មានប្រជាកសិករទូទៅក្នុងភូមិបានមកមើល និងរៀនសូត្រដកស្រង់បទពិសោធន៍ដែល ៥០%នៃអ្នកដែលបានចូលរួមរៀនសូត្រនេះពួកគេបានយកទៅអនុវត្តបន្ត។ ក្រុមផលិតចំនួន២០ក្រុម បានបង្កើតឡើងដែលភាគច្រើនសកម្មទៅលើក្រុមចិញ្ចឹមមាន់ ហើយនិងក្រុមដាំបន្លែ។ ជាពិសេសទៀតនោះ ក្រុមផលិតទាំងនេះបានធ្វើការផ្គត់ផ្គង់ផលិតផលកសិកម្មរបស់ពួកគាត់មកកាន់សហភាពសហគមន៍កសិកម្ម ហើយសហភាពសហគមន៍សិកម្មបន្តភ្ជាប់ផលិតផលទាំងនេះ ទៅកាន់ទីផ្សារក្នុងខេត្តសៀមរាបក៏ដូចជាខេត្តដទៃផ្សេងទៀតផងដែរ។ ការចូលរួមរបស់ស្ត្រីក្នុងគម្រោងមានបរិមាណច្រើនជាងបុរស។ តាមការសង្កេតឃើញថាស្ត្រីហាក់ដូចជាសកម្មក្នុងការចូលរួម ពួកគាត់មានភាពក្លាហានលើកនៅបញ្ហាកង្វល់នានារបស់ពួកគាត់ ហើយក៏ដូចជាការចែករម្លែកការគិតរបស់ពួកគាត់ ទៅកាន់សមាជិកផ្សេងទៀតរបស់សហគមន៍ជាពិសេសក្រុមបុរស។ ប្រហែល៣០%=៦០នៃចំនួនសរុប១៧០នាក់ ក្នុងចំនោមជួរគណៈកម្មការដឹកនាំក្រុមសរុប៣៣៥នាក់ នៃសហគមន៍កសិកម្មទាំងអស់បានចូលរួមក្នុងដំណើរការកសាង និងសមាហរណកម្មផែនការឃុំ ដែលដំណើរការក្នុងកម្រិតថ្នាក់ឃុំ ហើយនឹងធ្វើការសន្ទនាជាមួយអាជ្ញាធរថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ។ ពិសេសជាងនេះទៅទៀតនោះ មានស្ត្រី៥០%=១៧០នាក់ ក្នុងចំណោមថ្នាក់ដឹកនាំគណកម្មការសហគមន៍ទាំងអស់ចំនួន៣៣៥នាក់ បានកាន់តួនាទីក្នុងជួរថ្នាក់ដឹកនាំនៅបណ្តាសហគមន៍កសិកម្មទាំង២២ សហភាពសហគមន៍កសិកម្ម១ ក្រុមសន្សំ ២៥ក្រុម ហើយនឹងក្រុមផលិតចំនួន២០ក្រុមនៅក្នុងបណ្តាខេត្តគោលដៅទាំង៣មាន សៀមរាប ព្រះវិហារ ឧត្តរមានជ័យ។ ផ្អែកលើការវិភាគទៅលើកំណត់ត្រាប្រចាំខែ របស់កសិកដ្ឋានដំណាំ និង ចិញ្ចឹមសត្វគម្រូចំនួន១៦ ក្នុងគោលដៅគម្រោងក្នុងឆ្នាំ២០២០ ប្រាក់ចំនូលប្រចាំឆ្នាំពីផលរបរកសិកម្ម របស់សហគមន៍គោលដៅមានការកើនឡើងរង្វង់ ១៥% ដែលស្មើនឹងចំនួន ១ ០០២ ៥០០ រៀល ក្នុង១គ្រួសារ ក្នុង១ឆ្នាំ ចំនួននេះក៏រាប់បញ្ចូលទាំងប្រភពចំនូលដែលមិនមែនជាកសិកម្មតាមគ្រួសារផងដែរ។ ក្នុងដំណាក់កាលនៃការត្រៀមដកថយគម្រោងនេះ យើងនឹងផ្តោតលើះ

- ការកសាងនិងពង្រឹងសមត្ថភាពក្រុមផលិត ហើយនិងជំនាញដែលអាចធ្វើកសិកម្មធន់ទ្រាំនឹងអាកាសធាតុដោយនិរន្តភាព
- ពង្រឹងសមត្ថភាពសហគ្រិននារី និងអង្គការមហាជនទៅលើការភ្ជាប់ទីផ្សារ តាមរយះការគាំទ្រលើការអភិវឌ្ឍមុខជំនួញកសិកម្មរបស់សហភាពសហគមន៍កសិកម្ម និងសហគមន៍កសិកម្មដើម្បីធានាបាននូវការប្រតិបត្តិមុខជំនួញដោយរលូន
- ការពារសិទ្ធិកសិករដោយធ្វើអោយពួកគាត់ទទួលបាននូវអត្ថប្រយោជន៍គោលនយោបាយដែលមានតាមរយះការកសាងទំនាក់ទំនងជាមួយមន្ទីរកសិកម្ម ពាណិជ្ជកម្ម កិច្ចការនារី និងអាជ្ញាធរដែនដីជាដើម។

| គោលដៅរួមគម្រោង | លទ្ធផលរំពឹងទុកសម្រេចឆ្នាំ២០២០ |
|---|---|
| កសិករខ្នាតតូច ហើយនឹងក្រុមផលិតវិស័យកសិកម្មដែលស្ថិតក្នុងបន្ទាត់ក្រីក្រ ជាពិសេសស្ត្រី និង សហគមន៍ជនជាតិដើមភាគតិច ត្រូវបានផ្តល់អំណាចម្ចាស់ការលើផ្នែកសេដ្ឋកិច្ច និងសង្គមកិច្ច រួមបញ្ចូលដើម្បីអោយសម្រេចបាននូវការលូតលាស់ដោយសមធម៌និងសិទ្ធិស្មើភាពគ្នា | • កាត់បន្ថយ១៥% នៃកសិករគោលដៅគម្រោងដែលមានប្រាក់ចំនូលទាបជាងបន្ទាត់ក្រីក្រ នៅឆ្នាំ២០២២<br>• កើនឡើង២៥%នៃប្រជាជនសរុបក្នុងការចូលរួមធ្វើការសម្រេចចិត្តក្នុងកម្រិតថ្នាក់ក្រោមជាតិ និងថ្នាក់ ជាតិដើម្បីបង្កើនសិទ្ធិផ្នែកសេដ្ឋកិច្ច សង្គមកិច្ច បរិស្ថាន នយោបាយ និងវប្បធម៌<br>• បង្កើនអោយដល់ ៥០% នៃស្ត្រីគោលដៅក្នុងការកាន់តួនាទីជាអ្នកដឹកនាំអង្គការកសិករ និងរចនាសម្ព័ន្ធរបស់សហគមន៍ |

លទ្ធផលសម្រេចបានឆ្នាំ ២០២០

| | |
|---|---|
| ក្នុងកំឡុងពេលរាយការណ៍ឆ្នាំ២០២០នេះ មានការកែប្រែតិចតួចបើធៀបទៅនឹងទិន្នន័យគោលដែលបានរៀបចំឡើងដោយវីអេហ្វិក។ យ៉ាងណាក៏ដោយ ការអនុវត្តគម្រោងជាទូទៅនៅតែមានទំនាក់ទំនងគ្នាទៅនឹងគោលដៅជាយុទ្ធសាស្ត្រ និងគោលបំណងជាក់លាក់របស់គម្រោង ស្របតាមកម្មវិធីវីអេហ្វិករបស់ថ្នាក់តំបន់អាស៊ីអាគ្នេយ៍។ តាមការសង្កេតឃើញថាមានចំនួនស្ត្រីបានចូលរួមច្រើនក្នុងដំណើរការអនុវត្តគម្រោង យ៉ាងហោចណាស់ ៦០% ជាមធ្យម។ ម្យ៉ាងវិញទៀតបើទោះភាគរយចូលរួមរបស់ស្ត្រីខ្ពស់ជាងបុរសក៏ដោយ ប៉ុន្តែសំលែងរបស់ស្ត្រីនៅតែទាបនៅឡើយក្នុងការចូលរួមលើកជាមតិយោបល់ ដែលមើលទៅមិនទាន់អាចប្រកួតប្រជែងនឹងបុរសបាននៅឡើយ។<br>• ៣០%=៦០នាក់ នៃស្ត្រី១៧០នាក់ ក្នុងចំណោមគណកម្មការសហគមន៍កសិកម្មសរុប៣៣៥នាក់ បានចូលរួមក្នុងដំណើការកសាងផែនការ និងសមាហរណកម្មផែនការឃុំ ហើយព្រមទាំងពាំនាំការជជែកសន្ទនាពីបញ្ហាដែលបានលើកទៅកាន់ថ្នាក់ជាតិផងដែរ។<br>• ៥១%=១៧០នាក់នៃស្ត្រីក្នុងចំណោមថ្នាក់ដឹកនាំទាំង ៣៣៥នាក់ បានកាន់តួនាទីក្នុងជួរថ្នាក់ដឹកនាំ ក្នុងសហគមន៍កសិកម្ម២២ សហភាពសហគមន៍កសិកម្ម១ ក្រុមសន្សំ ២៥ និងក្រុមផលិត ២០ក្រុម នៃបណ្តាខេត្តគោលដៅទាំង៣មាន សៀមរាប ព្រះវិហារ ឧត្តរមានជ័យ។ | |
| គោលបំណងរួម | លទ្ធផលរំពឹងទុកសម្រេចឆ្នាំ២០២០ |
| ផ្តល់អំណាចម្ចាស់ការ ដល់កសិករខ្នាតតូច និងអង្គការមហាជន ក្នុងឃុំទាំង១៥ រវាងអន្តរខេត្ត សៀមរាប ឧត្តរមានជ័យ និងព្រះវិហារ ក្នុងការប្រើប្រាស់សិទ្ធិស្របច្បាប់ពួកគេដើម្បីទទួលបានសេវាសេដ្ឋកិច្ច និងសង្គមកិច្ចដោយនិរន្តរភាព | ▪ សំណើរឬផែនការអង្គការមហាជនចំនួន២២បានដាក់ចូលទៅក្នុងសមាហរណកម្មផែនការឃុំ ឬបានដាក់ស្នើទៅកាន់ដៃគូគាំទ្រដែលមានសក្តានុពលរៀងរាល់ឆ្នាំ<br>▪ ៥០%នៃស្ត្រីគោលដៅគម្រោងបានចូលរួមដោយសកម្មក្នុងការធ្វើសេចក្តីសម្រេចលើផ្នែកសេវាសេដ្ឋកិច្ច និងសង្គមកិច្ចទាំងនៅថ្នាក់ក្រោមជាតិ និងថ្នាក់ជាតិ<br>▪ អង្គការមហាជននីមួយៗអាចរកប្រាក់ចំណេញ១៥%ប្រចាំឆ្នាំ<br>▪ ១០% នៃកិច្ចសន្យាទិញលក់របស់អង្គការមហាជនមានការកើនឡើងប្រចាំឆ្នាំ<br>▪ ១០វេទិការពិគ្រោះ និងជជែកពិភាក្សាទៅលើគោលនយោបាយ ត្រូវបានរៀបំឡើងដោយអង្គការមហាជន<br>▪ ៤៥ករណី ដែលជាកង្វល់កសិករត្រូវបានចងក្រងលើកស្នើដោះស្រាយ ហើយ៥០%នៃបញ្ហា ឬកង្វល់ជុំវិញវិស័យកសិកម្មនិងការអភិវឌ្ឍសហគមន៍នេះត្រូវបានរាយការណ៍ថាបានដោះស្រាយរៀងរាល់ឆ្នាំ |
| លទ្ធផលសម្រេចបានឆ្នាំ ២០២០ | |
| ការចាប់ផ្តើមគម្រោងនៃឆ្នាំ២០២០ នៃផែនការយុទ្ធសាស្ត្រ៥ឆ្នាំ២០១៨-២០២២នេះ យើងសង្កេតឃើញថាលទ្ធផលដែលសម្រេចបានដោយការខិតខំប្រឹងប្រែងរួមគ្នារវាងអង្គការកែប្រែសហគមន៍ និងអង្គការវីអេហ្វិក គឺមានការលំបាកយ៉ាងខ្លាំង ដោយសារកត្តាវិបត្តិជំងឺរាតត្បាតកូវីត១៩ ទើបធ្វើអោយប៉ះពាល់ដល់ការអនុវត្តសកម្មភាពមិនបានរលូន តាមផែនការដែលមានលទ្ធផលសង្ខេបគឺ៖<br>• សហគមន៍កសិកម្ម ២២ បានរៀបចំផែនការជំនួញរបស់ខ្លួន ហើយបានបញ្ចូលផែនការទៅក្នុងសមាហរណកម្មផែនការថ្នាក់ឃុំរៀងខ្លួនៗ<br>• ៣០%=៥១នាក់ នៃចំនួនស្ត្រី១៧០នាក់ ក្នុងចំនោមគណកម្មការដឹកនាំសហគមន៍ ៣៣៥នាក់របស់សហគមន៍កសិកម្ម ក្នុងខេត្តទាំង ៣ ពួកគាត់បានចូលរួមក្នុងដំណើរការកសាងផែនការថ្នាក់ឃុំទាំងកម្រិតភូមិនិងឃុំ ដើម្បីត្រៀមបញ្ចូលកង្វល់ដែលជាបញ្ហាដើម្បីស្នើការគាំទ្រពីឃុំខ្លួន (ផ្អែកលើរបាយការណ៍យោងលើការចុះប្រជុំជាមួយគណកម្មការសហគន៍ ក្នុងកំឡុងពេលចុះត្រួតពិនិត្យប្រចាំឆ្នាំ) | |
| គោលបំណងជាក់លាក់ | លទ្ធផលរំពឹងទុកត្រូវសម្រេចឆ្នាំ២០២០ |
| ទី១៖ជម្រុញផលិតកម្មកសិកម្មដែលអាចធន់ទ្រាំនឹងអាកាសធាតុដោយនិរន្តភាព | • ស្ត្រីមកពីតាមអង្គការមហាជនអាចទទួលបាននូវកសិកដ្ឋានបង្ហាញគម្រូពីកសិកម្មចម្រុះដើម្បីអាចសិក្សារៀនសូត្រនិងអនុវត្តផ្ទាល់ពីកសិដ្ឋានគម្រូដែលជោគជ័យនេះ<br>• រៀបចំកសិកដ្ឋានបង្ហាញគម្រូចំនួន១តាមសហគមន៍កសិកម្មទាំង២២ ដើម្បីបង្ហាញពីខ្សែចង្វាក់ផលិតកម្មទៅដល់សមាជិកសហគមន៍កសិកម្ម<br>• កសាងសមត្ថភាពសមាជិកអង្គការមហាជនលើប្រព័ន្ធកសិកម្មដែលអាចធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ<br>• ផ្សព្វផ្សាយព័ត៌មានជុំវិញកម្រងផ្លូវច្បាប់ទៅលើសិទ្ធិកាន់កាប់ដីទៅដល់សមាជិកអង្គការមហាជន<br>• ជម្រុញអោយមានការទទួលបានការគ្រប់គ្រងកាន់កាប់ដីដោយសុវត្ថិភាពដល់សមាជិកអង្គ |

<table>
<tr><td></td><td>ការមហាជន<br>• ស្ត្រីបានចូលរួមសម្រេចចិត្ត និងសំដែងនូវតម្រូវការពួកគាត់ទៅលើសិទ្ធិពីសុវត្ថិភាពកាន់កាប់ប្រើប្រាស់ដីធ្លី<br>• ស្ត្រីជាកសិករមានការកើនឡើងក្នុងការទទួលបានសេវាផ្សព្វផ្សាយបច្ចេកទេសកសិកម្មហើយនឹងធនធានគាំទ្រ<br>• ផលិតផលក្នុងស្រុកដែលកសិករផលិតបានត្រូវបានធ្វើការចុះបញ្ជីអត្តសញ្ញាណកម្ម</td></tr>
<tr><td colspan="2">លទ្ធផលសម្រេចបានឆ្នាំ ២០២០</td></tr>
<tr><td colspan="2">• សរុប៤១៩នាក់(៧០%=២៩២ជាស្ត្រី) ទទួលបានចំនេះដឹងលើប្រព័ន្ធកសិកដ្ឋានដំណាំចម្រុះហើយនឹងអាចយកបច្ចេកទេសទៅអនុវត្តដែលអាចបន្សាំនឹងការប្រែប្រួលអាកាសធាតុ។ យើងសង្កេតឃើញថាយើងសម្រេចបាន១២៤%លើសពីផែនការបើធៀបទៅនឹងសូចនករក្នុងឆ្នាំនេះ<br>• មានកសិដ្ឋានគម្រូ៧ក្នុងចំនោម៩មានដំណើរការល្អក្នុងខេត្តសៀមរាប<br>• មានក្រុមផលិត២០ក្រុមបានចងក្រង(មានសមាជិកសុរប៩២នាក់ ហើយ៨០%ជាស្ត្រី) ក្នុងនោះមានប្រភេទផលិតផលសំខាន់៣ប្រភេទដែលក្រុមធ្វើការផលិតផ្គត់ផ្គង់ខ្សែចង្វាក់ផលិតកម្មដូចជា អង្ករ មាន់ ហើយនឹងបន្លែ ត្រូវបានកំណត់យកសម្រាប់ក្នុងខេត្តសៀមរាប ឧត្តរមានជ័យ<br>• ៥០%=១១សហគមន៍កសិកម្មក្នុងចំនោម ២២បានធ្វើការកំណត់ប្រភេទផលិតផលក្នុងខ្សែចង្វាក់ផលិតកម្ម ដូចជា ស្រូវអង្ករ បន្លែ មាន់ និងសាច់ជ្រូក ហើយសហគមន៍កសិកម្ម១១ក្នុងចំនោម២២នៃ៣ខេត្តនេះបានភ្ជាប់ទំនាក់ទំនងគ្នាយ៉ាងរឹងមាំជាមួយសមាជិកក្នុងការជម្រុញការប្រភេទផលិតផលរបស់ពួកគេទៅកាន់ខ្សែចង្វាក់ផលិតកម្មទីផ្សារ។ ក្នុងនោះក៏មានជាអ្នកប្រមូលទិញ និងតំណាងស្ត្រីជាសហគ្រិនដែលបានទទួលនូវការកសាងសមត្ថភាពក្នុងការភ្ជាប់ផលិតផលទៅកាន់ទីផ្សារ។<br>• សរុប ៣០១នាក់ ក្នុងនោះស្ត្រី២២១ទទួលបាននូវវគ្គបណ្តុះបណ្តាលទៅលើបច្ចេកទេសការធ្វើកសិកម្មដែលអាចធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ វាស្មើនឹង១៥%ធៀបទៅនឹងសូចនករ។ ហើយ៣៥%=១០៥នាក់ទទួលបានវគ្គបណ្តុះបណ្តាលដែលយកទៅអនុវត្តលើដំណាំបន្លែ និងការចិញ្ចឹកង្កែប។<br>• សរុបមាន១៦៣នាក់(១២៦នាក់=៧៧%ជាស្ត្រី) បង្កើនចំណេះដឹងដោយទទួលបាននូវព័ត៌មានផ្សព្វផ្សាយស្តីពីសិទ្ធិស្រប់ច្បាប់កាន់កាប់ដីធ្លី<br>• បញ្ហាដីធ្លី២ករណីក្នុងសហគមន៍កសិកម្ម២នៅឧត្តរមានជ័យ១បានដោះស្រាយរួច ហើយ១ករណីទៀតកំពុងដាក់ពាក្យបណ្តឹងទៅតុលាការ<br>• ៧៩%=៤២៣នាក់នៃស្ត្រីចំនោមអ្នកចូលរួមសរុប៥៣៤នាក់បានយល់ដឹងពីសិទ្ធិប្រើប្រាស់កាន់កាប់ដីធ្លី និងប្រភពនៃទំនាស់តាមរយៈការសហការផ្សព្វផ្សាយជាមួយអាជ្ញាធរនិងជំនាញតាមខេត្តគោលដៅរបស់ពួកគេ។ ក្នុងនោះមាន ៨០%=១៦៧នាក់ជាស្ត្រីក្នុងចំណោមអ្នកចូលរួម ២០៩នាក់ក្នុងការជជែកជាមួយអាជ្ញាធរមូលដ្ឋានអំពីដំណោះស្រាយលើវិវាទដីធ្លី។<br>• ១៣២នាក់ជាស្ត្រីក្នុងចំនោមសរុប១៦៥នាក់ ទទួលបាននូវការអនុវត្តគោលការកសិកម្មល្អ និងបច្ចេកទេសកសិកម្មទំនើប<br>• ផលិតផលកសិកម្ម១ត្រូវបានកំណត់អត្តសញ្ញាណ "ស្រូវផ្ការំដួល" សៀមរាបអង្ករ ដើម្បីត្រៀមស្នើសុំចុះបញ្ជីរ</td></tr>
<tr><td>ទី២៖ពង្រីការទទួលបាននូវការគាំទ្រដល់មនុស្សភេទដែលរងគ្រោះ និងការទទួលបានសេវាហិរញ្ញវត្ថុប្រកបដោយបរិយាបន្ន</td><td>• ស្ត្រីទទួលបាននូវការកសាងសមត្ថភាពលើមូលដ្ឋានគ្រឹះនៃការការគ្រប់គ្រងហិរញ្ញវត្ថុ<br>• ស្ត្រីទទួលបានការណែនាំផ្តល់ជូននូវបច្ចេកទេសដែលជួយសម្រួលដល់ស្ត្រីដែលទន់ខ្សោយ<br>• ចំនួនស្ត្រីដែលទទួលបានវគ្គបណ្តុះបណ្តាលកសាងសមត្ថភាពនិងមានលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុដែលផ្តល់សម្បទានល្អមកពីស្ថាប័នហិរញ្ញវត្ថុដែលមានសក្តានុពល<br>• សមាជិកអង្គការមហាជនជាស្ត្រីអាចកាន់តែសកម្មក្នុងការចូលរួមសម្រេចចិត្តជាមួយប្តី<br>• តាមបណ្តាអង្គការមហាជនក្នុងគោលដៅគម្រោងមានគោលនយោបាយដើម្បីផ្តល់ផលប្រយោជន៍ដល់ស្ត្រី<br>• អង្គការមហាជនក្នុងគោលដៅគម្រោងអាចមានលទ្ធភាពទទួលបានឥណទានដែលមានការប្រាក់ទាបពីគ្រឹះស្ថានហិរញ្ញវត្ថុដូចជាធនាគារអភិវឌ្ឍជនបទ ឬគ្រឹស្ថានមីក្រូហិរញ្ញវត្ថុផ្សេងៗ<br>• អំពីហឹង្សាលើស្ត្រីត្រូវបានកាត់បន្ថយ</td></tr>
<tr><td colspan="2">លទ្ធផលសម្រេចបានឆ្នាំ ២០២០</td></tr>
</table>

<table>
<tr><td colspan="2">
• ២៦៥នាក់(១៨៩=៧១%ជាស្រ្តី)បានចូលរួមប្រជុំតាមភូមិហើយនឹងទទួលវគ្គបណ្តុះបណ្តាលពីមូលដ្ឋានគ្រឹះនៃការគ្រប់គ្រងហិរញ្ញវត្ថុ និងរបៀបទទួលបានឥណទានដែលសមស្រប។<br>
• ឧបករណ៍ស្តីពីទស្សនទានយេនឌ័រ និងផែនទីបង្ហាញផ្លូវយេនឌ័រត្រូវបានផ្តល់ជូនស្រ្តីសហគមន៍គោលដៅ<br>
• ស្រ្តី៥០នាក់បានទទួលនូវសេវាហិរញ្ញវត្ថុពីសហគមន៍កសិកម្ម និងមីក្រូហិរញ្ញវត្ថុ<br>
• ស្រ្តី១២នាក់ដែលបានបណ្តុះបណ្តាលលើផែនទីបង្ហាញផ្លូវយេនឌ័របានលើកទឹកចិត្តអោយពួកគាត់មានផែនការគ្រួសារដើម្បីធ្វើការវាស់វែងពីការផ្លាស់ប្តូរតួនាទីនៃយេនឌ័រនិងទំនាក់ទំនងក្នុងគ្រួសារ<br>
• តំណាងសហគមន៍កសិកម្ម៣បានរាយការណ៍ថាពួកគេបានទទួលឥណទានពីមីក្រូហិរញ្ញវត្ថុ IDEMUTSU and ACLEDA Bank<br>
• ៩៦នាក់(៥៣=៥៥%ជាស្រ្តី) បានចូលរួមក្នុងដំណើរការផ្សព្វផ្សាយលើកកំពស់ការយល់ដឹង ហើយនឹងការប្រជុំដោយអង្គការCTOសហការជាមួយក្រុមប្រឹក្សាឃុំក្នុងតំបន់គោលដៅ អំពីបញ្ហាអំពើហឹង្សាក្នុងគ្រួសារ ឬលើស្រ្តី។<br>
• មាន១៥ករណីរាយការណ៍តាមរយះសហគមន៍កសិកម្ម១៥អំពីអំពើហឹង្សាលើគ្រួសារត្រូវបានដោះស្រាយ
</td></tr>
<tr><td>ទី៣៖ ជម្រុញស្រ្តីជាសហគ្រិនភាព</td><td>
• កសិកដ្ឋានគម្រូបង្ហាញពីគោលការណ៍សរីរាង និងកសិដ្ឋានបែប ការពារបិរស្ថានត្រូវបានរៀបចំ១កន្លែងដោយមានការគាំទ្របច្ចេ កទេសនិងឯកភាពពីមន្ទីរកសិកម្មខេត្ត<br>
• កសិករទទួលបានការបណ្តុះបណ្តាលពីគោលការណ៍ដំណាំ សរីរាង្គ និងកសិដ្ឋានបែបការពារបរិស្ថាន<br>
• កសិករទទួលបានការបណ្តុះបណ្តាលពីគោលការណ៍រៀបចំដំណាំដែលសន្សំសំចៃទឹកដើម្បីសម្របទៅនឹងការប្រែប្រួលអាកា សធាតុ (លក្ខខ័ណ្ឌទឹកភ្លៀងមិនគ្រប់គ្រាន់)<br>
• កសិករមានចំណេះដឹងពីការសន្សំសំចៃទឹក ហើយចំនួនស្រះទឹក ឬប្រព័ន្ធរក្សាស្តុកទឹកត្រូវបានបង្កើន៣០%ធៀបពីមុន<br>
• ផលិតកម្មដំណាំ ហើយនឹងបច្ចេកទេសប្រើប្រាស់ជីកំប៉ុសនិងការ ប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតចម្រៃបែបធម្មជាតិកើនឡើង ៣០% ធៀបនឹងពេលមុន
</td></tr>
<tr><td colspan="2">លទ្ធផលសម្រេចបានឆ្នាំ ២០២០</td></tr>
</table>

កសិករតែងតែខ្វះមូលដ្ឋានចំណេះដឹងទៅលើជំនញប្រើប្រាស់ និងគ្រប់គ្រងទឹកលើកសិដ្ឋានដំណាំបានអស់សក្តានុ ពលដើម្បីបម្រើការស្រោចស្រព្វតាមរូបភាពដែលសន្សំសំចៃទឹក ក៏ដូចជាវិធីបំលែងកាកសំណល់អោយទៅជាមាន ប្រយោជន៍ក្នុងវិស័យកសិកម្ម។ ពួកគាត់សុខចិត្តទិញផលិតផលស្រាប់ដែលខ្លះខ្ជាយថវិកាហើយជារបស់មានសារ ធាតុគីមីគ្រោះថ្នាក់ក៏ដោយជាជាងកែច្នៃ របស់ធនធានដែលមានស្រាប់អោយមានប្រយោជន៍។

ដូច្នេះគម្រោងបានផ្តល់វគ្គបណ្តុះបណ្តាលមានប្រយោជន៍ជាច្រើនទៅដល់ថ្នាក់ដឹកនាំរបស់សហគមន៍កសិកម្មទាំង១២ ដើម្បីអោយ ពួកគាត់អាចបន្តផ្សព្វផ្សាយចែករម្លែកទៅកាន់សមាជិករបស់គាត់ពេលក្រោយ។ ជាញឹកញាប់សមាជិកដែលទិញជីពីស ហគមន៍តែងតែសួរសំនួរពីរបៀបប្រើប្រាស់ជី ប៉ុន្តែពេលខ្លះយើងសង្កេតឃើញថាអ្នកទទួលខុសត្រូវគ្រប់គ្រងជំនួញ ជីនេះមិនទាន់បានឆ្លើយសំនួររបស់អ្នកប្រើប្រាស់បានត្រឹមត្រូវនៅឡើយ។ ជាការឆ្លើយតបនឹងក្តីកង្វល់នេះ គម្រោង បានទាក់ទងទៅក្រុមហ៊ុនដែលផ្គត់ផ្គង់ជី ហើយនឹងមន្ត្រីជំនាញពីមន្ទីរកសិកម្មមកផ្តល់វគ្គបណ្តុះបណ្តាលតាមសហគមន៍នីមួយៗ ទៅលើការគ្រប់គ្រងប្រើប្រាស់ជីនិងថ្នាំពុលកសិកម្មទៅដល់ថ្នាក់ដឹកនាំសហគមន៍២០៧នាក់ ក្នុងនោះ ស្ត្រី១២៥នាក់។ ក្រោយចប់វគ្គ ហើយមានការចុះតាមដានទៅលើករណីនេះ អ្នកចូលរួមភាគច្រើនបានបញ្ជាក់ថា វគ្គបណ្តុះបណ្តាលពីប្រធានបទនេះពិតជាជួយបង្កើនចំណេះដឹងពួកគាត់ដែលមាន៦០%នៃអ្នកចូលរួមបានយល់ពី ការប្រើប្រាស់ត្រឹមត្រូវ ហើយពួកគាត់អាចពន្យល់និងណែនាំទៅដល់កសិករដំទៃពីវិធីប្រើប្រាស់ជីនិងថ្នាំគីមីបានត្រឹ មត្រូវតាមក្បួនបច្ចេកទេស។ ឯកសារបណ្តុះបណ្តាលមួយសេរីបានផ្តល់ជូន ជុំវិញប្រធានបទការដាំដុះបែបសរីរាង្គ និងការដាំដុះដែលធ្វើអោយប្រសើរដល់បរិស្ថាន ត្រូវបានរៀបចំដោយមានការឯកភាពពីមន្ទីរជំនាញផងដែរពោល គឺឯកសារចំលងមេរៀនត្រូវបានត្រូវបានផ្តល់ជូនដល់សិក្ខាកាមក្រោយវគ្គបណ្តុះបណ្តាល។ កសិករ២១០៦នាក់ ក្នុង ២៥០០នាក់មកពី១២សហគមន៍ និងក្រុមសន្សំប្រាក់ចាស់ថ្មី២៥ក្រុមក៏ទទួលបាននូវវគ្គបណ្តុះបណ្តាលនេះផងដែរ។ ក្រៅពីវគ្គនេះកសិករ ២១០៦នាក់ក្នុងចំនោម២៥០០នាក់ក៏ទទួលបានការបណ្តុះបណ្តាល និងការផ្សព្វផ្សាយអំពីប្រធានបទប្រសិទ្ធិភាពនៃការគ្រប់គ្រងនឹងប្រើប្រាស់ទឹកលើការដាំដុះ ដែលអាចសម្របទៅនឹងការប្រែប្រួលអាកាសធាតុ។ ២៥%នៃកសិករ២១០៦នាក់ ដែលទទួលបានការបណ្តុះបណ្តាលរាយការណ៍មកថាមានការកើនឡើងនូវការ គ្រប់គ្រងសមត្ថភាពស្តុកទឹក ដូចជាការបង្កើនចំនួនពាងឬធុងទឹកដើម្បីប្រមូលទឹកភ្លៀងរក្សាទុកសម្រាប់ប្រើប្រាស់ ក្នុងខែប្រាំងហើយនឹងស្តារស្រះទឹកអោយមានសមត្ថភាពបង្រុងទឹក ដើម្បីបំលែងជាប្រព័ន្ធដំណក់ទឹក សម្រាប់ស្រោចស្រព្វសួនដំណាំ។ ៣០%នៃកសិករ២១០៦នាក់ដែលទទួលបានការបណ្តុះបណ្តាលមានការថយចុះការប្រើប្រាស់ ថ្នាំគីមី ឬបានប្រើជីនិងថ្នាំគីមីត្រឹមត្រូវតាមបច្ចេកទេស ហើយកសិករខ្លះងាកមកប្រើបច្ចេកទេសតាមបែបធម្មជាតិ ជំនួសវិញដោយបានបទពិសោធន៍ពីវគ្គបណ្តុះបណ្តុល។ កសិដ្ឋានបង្ហាញគម្រូពីការប្រើប្រព័ន្ធដំណក់ទឹកចំនួន៩កន្លែង ត្រូវបានរៀបចំនៅតាមសហគមន៍ទាំង១២ ហើយតាមរយៈកសិដ្ឋានគម្រូនេះ វាបានផ្តល់ការបង្ហាញទៅដល់កសិករ២២៥នាក់បានចូលរួមរៀនសូត្រយកបទពិសោធន៍ទៅលើទីវាលនៃកសិកដ្ឋានគម្រូនេះផ្ទាល់តែម្តង។

បទពិសោធន៍ឬមេរៀនដែលរៀនសូត្រពីគម្រោង

-ជំងឺកូវីត១៩បានផ្ទុះឡើងនៅដើមឆ្នាំ បើមើលទៅលើឥទ្ធិពលនៃផលប៉ះពាល់វា យើងគិតថាមិនអាចអនុវត្តសកម្មភាពសកម្មភាពគម្រោងបានចប់ទាន់ពេលវេលាឡើយ។ យ៉ាងណាក៏ដោយ យើងបានរៀនពីបញ្ហានេះជាច្រើន ដើម្បីអាចបត់បែនបាននៅក្នុងស្ថានភាពបញ្ហាដ៏លំបាកនេះ ដោយយើងទទួលបាននូវការណែនាំ នូវមធ្យោបាយប្រព័ន្ធបណ្តាញសង្គមថ្មីៗ ដែលបង្កើតឡើងប្រើប្រាស់ដើម្បីភ្ជាប់ទំនាក់ទំនងដូចជា Zoom Go Meeting Telegram Messegner ជាដើម ដើម្បីដោះស្រាយចំពោះការរាំងស្ទះការជួបជុំដោយការរិតត្បិតវិធានការពារការឆ្លងរីករាលដាលជំងឺកូវីត១៩ ដោយការជួបប្រជុំតាម Online ជំនួសអោយការជួបប្រជុំផ្ទាល់ដែលបម្រាមមិនអនុញ្ញាត្តិ ឃើញថាមានប្រយោជន៍និងប្រសិទ្ធិភាពដែរ។

-គម្រោងពិចារណាចង់ជួយលើការវេចខ្ចប់ ដែលអាចដាក់លក់នៅលើទីផ្សារ។ គម្រោងបានរៀនពីចំនុចនេះដោយឃើញថាការចេះមានជំនាញទៅលើការដាំដុះតែមួយមុខគឺមិនអាចជួយអោយកសិករជោគជ័យផ្លាស់ប្តូជីវភាពនិងសេដ្ឋកិច្ចបាននៅឡើយទេ ដូច្នេះកសិករក្រីក្រត្រូវប្រមាច់បញ្ចូលគ្នាជាក្រុម ដែលអាចទទួលបាននូវការចូលរួមនូវគម្រូនៃក្រុមណាមួយ ដើម្បីពួកគាត់អាចសិក្សាបន្ថែមនិងអាចទទួលបានការលើកទឹកចិត្តគ្នាទៅវិញទៅមកតាមរយៈជម្រុញលើកទឹកចិត្តរវាងគ្នានឹងគ្នាក៏ដូចជាការប្រកួតប្រណាំងគ្នាដើម្បីធ្វើកិច្ចការអ្វីមួយអោយបានល្អដូចគ្នា។

-ការអូសបន្លាយនៃជំងឺរាតត្បាតកូវីត១៩បានធ្វើអោយមានឧបសគ្គរវាងទំនាក់ទំនងអន្តប្រទេសច្រើនសណ្ឋានផ្សេងគ្នាៗ ដូចជាការរិតត្បិតការដើរហើរឆ្លងកាត់ទៅវិញទៅមករវៀងប្រជាជននិងប្រជាជន សកម្មភាពដោះដូរសេដ្ឋកិច្ចឆ្លងព្រំដែន ការអនុវត្តគោលការរក្សាគម្លាតសង្គមដែលធ្លាប់មានជាប្រពៃណីបានប្រែក្លាយទៅជារបៀបនៃការប្រាស្រ័យទាក់ទងគ្នាថ្មីផ្សេងទៀតដើម្បីអាចបន្សាំទៅនឹងស្ថានភាពនេះ។ ទន្ទឹមនឹងនោះផងដែរប្រជាជនក្នុងស្រុកក៏បានរៀនពីការពង្រឹងសមត្ថភាពពួកគេដើម្បីកសាងភាពស៊ាំទៅនឹងស្ថានភាពសេដ្ឋកិច្ចនិងសង្គមកិច្ចជាបណ្តើៗ។

**២.ខេត្តឧត្តរមានជ័យ**

**គម្រោង(LRP)**

| គោលបំណងគំរោង | លទ្ធផលរំពឹងទុក |
|---|---|
| ១.ពង្រឹងភាពអង់អាចផ្នែកសេដ្ឋកិច្ចដល់ប្រជាសហគមន៍ព្រៃឈើជាពិសេសស្ត្រី និងយុវតីនៅក្នុងក្រុងសំរោង និងស្រុកបន្ទាយអំពិល តាមរយៈ ការគាំទ្រសិទ្ធិជាមូលដ្ឋាន ចូលរួមក្នុងការគ្រប់ គ្រងព្រៃសហគមន៍និងការកែច្នៃអនុផលព្រៃឈើ | ១.១. សមាជិកសហគមន៍ចំនួន០៣ (សហគមន៍ព្រៃឈើរំដួលវាសនា សហគមន៍ព្រៃឈើសំរែកព្រៃស្រស់ សហគមន៍ព្រៃឈើវត្តនរុក្ខា) និងបណ្តាញសហគមន៍ព្រៃឈើប្រចាំខេត្ត ដែលមានសមាជិកសហគមន៍ ព្រៃឈើសរុប៣២៦គ្រួសារ បានយល់ច្បាស់អំពីការបង្កើតសហគមន៍ព្រៃឈើ អត្ថប្រយោជន៍នៃការបង្កើតសហគមន៍ព្រៃឈើ ព្រំប្រទល់ព្រៃសហគមន៍ ព្រមទាំងបានចូលរួមក្នុងសកម្មភាពការពារ និងគ្រប់គ្រងព្រៃ សហគមន៍របស់ពួកគាត់។ |
| ៣. លើកកម្ពស់ការយល់ដឹង និងការអនុវត្តរបស់សិស្សានុសិស្ស គណៈកម្មការទ្រទ្រង់សាលា និងលោកគ្រូ-អ្នកគ្រូក្នុង សាលាគោលដៅចំនួន២០ ក្នុងក្រុងសំរោង ស្រុកបន្ទាយអំពិល ខេត្តឧត្តរមានជ័យ លើមុខវិជ្ជាបំណិនជីវិតក្នុងសាលារៀន។ | ៣.១. លោកគ្រូ-អ្នកគ្រូ សិស្សានុសិស្ស និងគណៈគម្មការទ្រទ្រង់សាលា ប្រមាណ៥0% នៅក្នុងសាលាគោលដៅចំនួន២០ នៃក្រុងសំរោង និងស្រុកបន្ទាយអំពិលមានការយល់ដឹងកាន់តែច្បាស់អំពីកម្មវិធីបំណិនជីវិត នៅតាមសាលារៀន ព្រមទាំងចូលរួមជំរុញការអនុវត្តិកម្មវិធីបំណិន ជីវិតក្នុងសាលារៀនរបស់ពួកគាត់អោយបានល្អបន្តទៅមុខជាគម្រូ។<br>៣.២. សាលាចំនួន០៥ ក្នុងចំណោមសាលាគោលដៅចំនួន២០ បាន បញ្ចូលមុខវិជ្ជាបំណិនជីវិតទៅក្នុងកម្មវិធីសិក្សា ដោយមានម៉ោងសិក្សា អំពីមេរៀនបំណិនជីវិតច្បាស់លាស់ ព្រមទាំងមានការជំរុញការអនុវត្ត កម្មវិធីបំណិនជីវិតតាមសាលាទាំងនោះបានយ៉ាងល្អប្រសើរ។ |
| ៤.លើកកំពស់ការកសាងសមត្ថភាពធន់ទ្រាំ និងការប្រែប្រួលអាកាសធាតុ និងរៀបចំយន្តការ គ្រប់គ្រងគ្រោះមហន្តរាយថ្នាក់ឃុំជាមួយឃុំគោលដៅទាំង៤ | ៤.១-ជនងាយរងគ្រោះ មានកុមារ ចាស់ជរា គ្រួសារក្រីក្រ ក្នុងឃុំគោលដៅគម្រោងទាំង៤ អាចធន់ទ្រាំនឹងការប្រែប្រួលអាកាសធាតុ និងត្រៀមលក្ខណៈបង្ការ ដើម្បីអាចឆ្លើយតបគ្រោះមហន្តរាយដែលកើតឡើង។ |
| ១១.ជំរុញការអនុវត្ត គោលនយោបាយ និងគោលការណ៍ផ្ទៃក្នុងរបស់អង្គការកែប្រែសហគមន៍ តាមរយៈការពង្រឹងសមត្ថភាពគណៈគ្រប់គ្រង បុគ្គលិក លើការគ្រប់គ្រង ត្រួតពិនិត្យការអនុវត្តន៍គម្រោង និងស្ថាប័ន។ | ១១.១. បុគ្គលិកអង្គការកែប្រែសហកមន៍ ចំនួន៦នាក់/ស្រី៣នាក់ ទទួលបានចំណេះដឹងថ្មីៗ តាមរយៈការចូលរួមសិក្ខាសាលា ការប្រជុំបណ្តាញអង្គការដៃគូរនានាទាំងក្ន និងក្រៅខេត្ត។<br>១១.២. លក្ខន្តិកៈ និងគោលនយោបាយផ្ទៃក្នុង របស់អង្គការកែប្រែសហគមន៍ត្រូវបានកែ សម្រួល និងត្រួតពិនិត្យឡើងវិញ ហើយទាំងបុគ្គលិក ទាំងគណៈគ្រប់គ្រង ចូលរួមអនុវត្តិគោ លការណ៍ ឬច្បាប់ដែលបានកែសម្រួលរួចនេះដោយមានប្រសិទ្ធិភាព។ |
| ១២.ពង្រឹងដំណើរការគាំពារកុមារមានភាពប្រសើរឡើងជាងមុន | កុមារចំនួន ៧០០នាក់/កុមារី៤១០នាក់ ស្ថិតនៅសង្កាត់សំរោង បន្សាយរាក់ និង ឃុំគោកខ្ពស់ អាចទទួលបានការគាំទ្រ និងអត្ថប្រយោជន៍ពីកម្មវិធីអភិឌ្ឍសហគមន៍ តាមរយៈ ការគួរសារ កម្មវិធីសប្បាយៗ ក្លឹបកុមារ និងការលើកកំពស់សិទ្ធិក្នុងសាលារៀន។ |

ចាប់ពីខែមករា ដល់ ខែធ្នូ ឆ្នាំ២០២០នេះ អង្គការកែប្រែសហគមន៍ បានអនុវត្តសកម្មភាពយោងទៅតាមគម្រោងផែនការប្រចាំឆ្នាំដែលសម្រេចបានតាមលទ្ធផលរំពឹងទុកសំខាន់ៗដូចខាងក្រោមៈ

សង្ខេបលទ្ធផល១.១៖

សមាជិកសហគមន៍ព្រៃឈើចំនួនសរុប១៥០នាក់ ក្នុងនោះស្រីចំនួន៨៩នាក់ បានយល់ដឹងពីគោលការណ៍ណែនាំបង្កើតសហគមន៍ព្រៃឈើ និងសហគមន៍តំបន់ការពារធម្មជាតិ និងអត្ថប្រយោជន៍នៃការបង្កើតសហគមន៍។ គណៈកម្មការសហគមន៍ព្រៃឈើចំនួន៣សហគមន៍បានជួបប្រជុំគ្នាម្តងរាយការណ៍ពីការរីកចំរើន បញ្ហាដែលកើតមាន និងផែនការបន្តបង្ហាញដល់អាជ្ញាធរសង្កាត់ ឃុំ និងសង្កាត់រដ្ឋបាលព្រៃឈើ និងបានអនុវត្តផែនការរបស់ពួកគាត់។ ល្បាតព្រៃចាប់រណាយន្តបាន១៣គ្រឿង គោយន្ត២គ្រឿង និងមនុស្ស៤នាក់ ព្រមទាំងមានការដាក់ពាក្យបណ្តឹងទៅតុលាការ។ ការដាក់សំណើរទៅសុំបង្កើតតំបន់អេកូទេសចរណ៍ ត្រូវបានយល់ព្រម និងសម្រេចដោយអភិបាលខេត្តឧត្តរមានជ័យ។ ជនល្មើស១៦នាក់ដែលបានកាប់រានដីសហគមន៍ព្រៃឈើវតនរុក្ខាប្រហែល៦០០ហិកតា ត្រូវបានដាក់ពាក្យបណ្តឹងទៅតុលាកាដោយប្រធានគណៈកម្មការសហគមន៍ព្រៃឈើ។ បទល្មើស១ករណី ដែលបានចូលទៅរស់នៅខុសច្បាប់ក្នុងសហគមន៍ភ្នំដងរ៉ែកសម្រែកព្រៃស្រស់ ត្រូវបានដោះសាយដោយមានការចូលរួមពីលោកអភិបាលរងស្រុកបន្ទាយអំពិល នាយសង្កាត់រដ្ឋបាលព្រៃឈើបន្ទាយអំពិល នាយរងផ្នែករដ្ឋបាលព្រៃឈើ ជំទប់ទី១ឃុំគោកខ្ពស់ ប្រធានការិយាល័យកសិកម្មស្រុក ប្រធានគណៈកម្មការសហគមន៍ព្រៃឈើ។ គណៈកម្មការសហគមន៍ព្រៃឈើចំនួន២នាក់ ក្រៅពីប្រធានគណៈកម្មការសហគមន៍ព្រៃឈើភ្នំដងរ៉ែកសម្រែកព្រៃស្រស់ត្រូវបានបង្រៀនអោយចេះសសេរសំណើរ និងទូទាត់ថវិកានៅពេលស្នើសុំថវិការពី អង្គការកែប្រែស

ហាគមន៍។ សហគមន៍ព្រៃឈើភ្នំដងរ៉ែកសម្រែកព្រៃស្រស់ សហការណ៍ជាមួយរដ្ឋបាលព្រៃឈើបានដាំកូនឈើ នៅតំបន់វិចរិលក្នុងព្រៃសហគមន៍បានចំនួន២៥០ដើម និងដើមក្បោកចំនួន៥០ដើម នៅលើផ្ទៃដី១ហិកតា ដែលមានអ្នកចូលរួមចំនួន៣២នាក់ ស្រី៧នាក់ រហូតមកដល់ពេលនេះដើមឈើដែលបានដាំមានការដុះលូតលាស់ទាំងអស់។ គណៈកម្មការសហគមន៍ព្រៃឈើភ្នំដងរ៉ែកសម្រែកព្រៃស្រស់ បានត្រួសត្រាយផ្លូវបណ្តោយប្រវែង៧០០ម៉ែត្រ និងទទឹង៥ម៉ែត្រួចសម្រាប់បង្កើតជាផ្លូវវង់ទស្សនាចរណ៍ នៃតំបន់ទេសចរណ៍ក្នុងសហគមន៍។ សហគមន៍បានយល់ដឹងពីរៀបធ្វើផែនការតាមភូមិដើម្បីបញ្ចូលមកថ្នាក់ឃុំ ពួកគាត់បានយកផែនការមកពិគ្រោះយោបល់ថ្នាក់ភូមិ និងលើកឡើងពីតម្រូវការដាក់ចូលក្នុងផែនការ ជាពិសេសតម្រូវ ការទាក់ទងនឹងការគ្រប់គ្រងសហគមន៍ព្រៃឈើរបស់ពួកគាត់ មានដូចជា៖ការបង្កើតតំបន់ទេសចរណ៍ ល្បាតព្រៃ ធ្វើផ្លូវភ្លើង ដាំដើមឈើឡើងវិញ ធ្វើផ្លូវក្នុងព្រៃសម្រាប់ទេសចរណ៍ ដោយលោកមេឃុំគោកខ្ពស់បានសន្យានឹងបែងចែកថវិការបស់ឃុំខ្លះ គាំទ្រដល់ផែនការសហគមន៍ព្រៃឈើសម្រាប់ឆ្នាំ២០២១។ រដ្ឋបាលព្រៃឈើ និងក្រុមប្រឹក្សាឃុំសង្កាត់ នៅតែបន្តជួយទុបស្កាត់បទល្មើសនៅក្នុងព្រៃសហគមន៍ទាំង៣ (សហគមន៍ព្រៃឈើភ្នំដង រ៉ែកសម្រែកព្រៃស្រស់ រំដួលវាសនា និងរតនរុក្ខា)។ សហគមន៍ព្រៃស្រស់បានភ្ជួរដីដែលបានដាំដុះកូនឈើបានចំនួន២ហិកតាដើម្បីការពារភ្លើងឆេះព្រៃ និងធ្វើផ្លាកសហគមន៍ភ្នំដងរ៉ែកសម្រែកព្រៃស្រស់ មានប្រវែង០.៦មគុណ២.៥ម៉ែត្រមួយផ្ទាំង និងថ្នាលបណ្តុះកូនឈើ១។ គណៈកម្មការសហគមន៍ព្រៃឈើ ក្បាលអូរសូភីគីរីព្រៃស្រោង៤នាក់ បានចូលឆ្លើយបំភ្លឺតាមការកោះហៅរបស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តឧត្តរមានជ័យតាមរយៈ សំណុំរឿងពាក្យបណ្តឹងព្រហ្មទណ្ឌរបស់សហគមន៍ព្រៃឈើ កាលពីថ្ងៃទី០៥ ខែមីនា ឆ្នាំ២០២០ តាមរយៈការសួរឆ្លើយនៅក្នុងរឿងនេះគណៈកម្មការ សហគមន៍ព្រៃឈើសូមសំនូមពរ អោយតុលាការចាត់វិធានការតាមនីតិវិធីច្បាប់ និងធ្វើកំណត់ហេតុជាចុងក្រោយ។ ពាក្យបណ្តឹងរបស់ខណ្ឌរដ្ឋបាលព្រៃឈើ តាមរយៈរបាយការណ៍របស់សហគមន៍ព្រៃឈើរតនរុក្ខា តុលាការបានដកហូតដីចំនួន០៩ហិកតាពីជនល្មើស២នាក់ប្រគល់ជូនសហគមន៍ វិញនៅថ្ងៃទី០៧ តុលា ឆ្នាំ២០២០។

សង្ខេបលទ្ធផលទី៣.១៖

ប្រធានការិយាល័យបឋមនៃមន្ទីរអប់រំយុវជននិងកីឡា ជាមួយអ្នកសម្របសម្រួលអង្គការកែប្រែសហគមន៍ បានយល់ដឹងកាន់តែច្បាស់ អំពីកម្មវិធីបំណិនជីវិតនៅតាមមូលដ្ឋាន មានដូចជាម៉ោងបំណិនជីវិតសម្រាប់សាលាបឋមសិក្សារបស់ក្រសួងអប់រំ ជំហ៊ានរបស់ការសិក្សាបំណិនជីវិត មុខវិជ្ជាបំណិនជីវិតដើម្បីយកទៅបង្រៀនបន្តដល់សាលាគោលដៅទាំង២៣សាលា។ សាលា២៦ ក្នុងកំរ៉ង៥ ស្ថិតនៅក្នុង២ឃុំ ៣សង្កាត់ មានសំរោង បន្សាយរាក់ កូនក្រៀល ឃុំពង្រនិងឃុំគោកខ្ពស់ បានទទួលសម្ភារៈថែរក្សាការពារអនាម័យឆ្លងជំងឺCOVID19រួមមាន៖

1.សាប៊ូលាងដៃចំនួន២៦កេះ

2.សម្ភារះបាញ់មើលកំដៅចំនួន៥២គ្រឿង

3.ម៉ាស់ពេទ្យ ចំនួន៥២ប្រអប់

4.អាកុលលាងដៃ(គុណភាពស្របតាមស្តង់ដាសុវត្ថិភាព) ចំនួន៥២លីត្រ

5.ប្រដាប់បាញ់អាកុលចំនួន៥២ដប

សម្ភារៈទាំងអស់ខាងលើជាតម្រូវការចាំបាច់ របស់សាលាដែលកំពុងតែខ្វះខាតតាមសាលានីមួយៗក្នុងការជួយការពារ និងទុកស្កាត់ កូវីត១៩។

សង្ខេបលទ្ធផលទី៤.១៖ ត្រៀមបង្កា និងឆ្លើយតបគ្រោះមហន្តរាយ

អង្គការកែប្រែសហគមន៍បានសហការជាមួយអាជាធរភូមិចំនួន៣១ សង្កាត់/ឃុំចំនួន៥ និងក្នុងស្រុកចំនួន៣ ធ្វើការចែកស្បៀងសង្គ្រោះបន្ទាន់ និង ផ្សព្វផ្សាយពីការលាងសម្អាតដៃ នៃការរីករាល និងវិធីសាស្រ្តការពារទុបស្កាត់ពីជម្ងឺCOVID-19 ដល់គ្រួសារកុមារគូសារក៏ក្រ និងគ្រួសារក្រ១ ដែលងាយរងគ្រោះដោយសារផលប៉ះពាល់ពីជម្ងឺកូវីត១៩ ចំនួន២៤៨គ្រួសារ ដែលក្នុងនោះមានគ្រួសារកុមារគូសារ ចំនួន២១០គ្រួសារ ដែលស្បៀងទទួលបាន ទៅតាមសមាមាត្រចំនួនសមាជិកគ្រួសារ ច្រើនឬតិចមាន៨ប្រភេទ ១/អង្ក ២/មី ៣/ត្រីខ ៤/ប្រេងឆា ៥/ទឹកត្រី ៦/ទឹកស៊ីអ៊ីវ ៧/ស្ករស និង៨/អំបិល។ ប្រជាជននៅតំបន់គោលដៅចំនួន៣៤ភូមិ ត្រូវនឹង៥ឃុំសង្កាត់ ដែលមានអ្នកចូលរួមសរុប ១,៦២២នាក់ក្នុងនោះស្រី១,១០៩នាក់ មានការយល់ដឹងនិងអនុវត្តពីការលាងសម្អាតដៃ និងវិធីសាស្រ្តការពារទុបស្កាត់ពីជម្ងឺCOVID-19។

សង្ខេបលទ្ធផលទី៨៖ ការប្រមូលសារប្រចាំឆ្នាំ

២០២០ ស៊ីធីអូ បានធ្វើការប្រមូលសារសម្រេចបានប្រមាណ១00% បើធៀបនឹងសុច្ចករ ដែលមានចែងនៅក្នុងផែនការប្រចាំឆ្នាំ ដែលមានកុមារគាំពារចំនួន១០៦៩ ស្រី៥៩១នាក់។

សង្ខេបលទ្ធផលទី៨៖ ការអភិវឌ្ឍស្ថាប័ន

ការអនុវត្តផែនការឆ្នាំ២០២០ត្រូវបានឆ្លុះបញ្ចាំង និងលើកទិសដៅបន្តឆ្នាំ២០២១ដល់២០២៣ ដែលមានសមាសភាពចូលរួមមាន: ប្រធានការិយា

ល័យបឋមនៃមន្ទីរអប់រំ នាយរងខណ្ឌរដ្ឋបាលព្រៃឈើឧត្តរមានជ័យនិងនាយសង្កាត់ ប្រធានកំម្រងមកពីប្រាំសាលា (ពង្រ សំរោង បន្សាយរាក់ កូនក្រៀល និងគោកខ្ពស់) មេឃុំគោកខ្ពស់និងក្រុមប្រឹក្សាសង្កាត់សំរោង កូនក្រៀល និងពង្រ (ចុងកាល់) នាយកសាលាពោធិវង្ស ត្នោត ឈើស្លាប់ គោកខ្ពស់ គណៈកម្មការសហគមន៍ព្រៃឈើមាន រតនវុក្ខា ភ្នំដងរែកសម្រែកព្រៃស្រស់ រំដួលវាសនា និងរលុះធំ។ អង្គការCTOបានពិគ្រោះយោបល់លើបញ្ហាជាចម្បង ចាត់អាទិភាពបញ្ហា និងរកដំណោះស្រាយរួម សំដៅធ្វើឱ្យគម្រោងអាចលើកយកបញ្ហា និងតម្រូវការជាអាទិភាពទាំងនេះដើម្បីដាក់ចូលក្នុងផែនការឆ្លើយតបសម្រាប់ ឆ្នាំ២០២១ដល់២០២៣ និងបន្ទាប់មកបានពិភាក្សាជាមួយបុគ្គលិកអង្គការកែប្រែសហគមន៍ទាំងអស់ ដែលផ្តោតលើការអប់រំ ការគ្រប់គ្រងសហគមន៍ព្រៃឈើ ការអភិវឌ្ឍស្ថាប័ន និងធ្វើទៅអាក់សិនអេតចុងក្រោយ។ ក្រុមសន្សំចំនួន២០ក្រុម និងក្រុម ធនាគារស្រូវចំនួន៨នៅតែមានដំណើរការជាប្រចាំ ដូចជាការខ្ចីសងជាធម្មតា។

## III. របាយការណ៍ហិរញ្ញវត្ថុ

| គម្រោង | ចំណូលប្រចាំឆ្នាំ | ចំណាយប្រតិបត្តិការ | ចំណាយកម្មវិធី | សមតុល្យឆ្នាំមុន | សមតុល្យ |
|---|---|---|---|---|---|
| WeEffect | 32,696.88USD | 18,177.75 USD | 14,820.40 USD | 342.86USD | 41.59 USD |
| PACT/USAID | 24,033.89 USD | 9,806.94.00 USD | 16,224.01 USD | 4,158.97 USD | 2,161.91 USD |
| AAC_LRP | 53,987.69 USD | 15,172.11 USD | 39,229.83.00 USD | 4,575.15 USD | 4,160.90 USD |

## IV. ផែនការទិសដៅការងារបន្ត

<u>ខេត្តសៀមរាប</u>

<u>គម្រោងទី១៖</u>

១-ចុះសិក្សាកំណត់អ្នកទទួលផលគម្រោងថ្មី
២-កសាងទិន្នន័យគោល និងធ្វើបច្ចុប្បន្នភាពទិន្នន័យអ្នកទទួលផលគម្រោង
៣-ចុះសិក្សាតម្រូវការពីអ្នកទទួលផលគម្រោង
៤-ជ្រើសរើសអ្នកសម្របសម្រួលបណ្តុះបណ្តាលវគ្គពន្លកអាជីវកម្ម និងរៀបចំកិច្ចតែងការមេរៀន
៥-បើកវគ្គបណ្តុះបណ្តាលពន្លកអាជីវកម្មចំនួន៥វគ្គដល់សហគ្រិននារីវ័យក្មេង
៦-បើកវគ្គបណ្តុះបណ្តាល៥វគ្គលើប្រធានបទ សិទ្ធិសេដ្ឋកិច្ចសង្គមដល់សហគ្រិននារីវ័យក្មេង
៧-រៀបចំពិធីចែកវិញ្ញាប័នប័ត្របញ្ចប់វគ្គបណ្តុះបណ្តាលដល់សហគ្រិននារីវ័យក្មេង
៨-ចុះសិក្សាដើម្បីកំណត់ជ្រើសរើសសហគ្រិននារីវ័យក្មេង២៥នាក់សម្រាប់ការចុះតាមដាន និងបង្វឹកអាជីវកម្ម
៩-ជ្រើសរើសគ្រូបង្វឹកការធ្វើអាជីវកម្ម និងការចុះធ្វើការបង្វឹកជាប្រចាំដល់សហគ្រិននារីទាំង២៥រូប
១០-ដឹកនាំសហគ្រិននារីវ័យក្មេងចុះទស្សនកិច្ចសិក្សាចំនួន២លើក
១១-សម្របសម្រួលកិច្ចប្រជុំកសាងទំនាក់ទំនងកិច្ចសហប្រតិបត្តិការធុរកិច្ចជាមួយអ្នកពាក់ព័ន្ធ
១២-រៀបចំពិធីប្រកួតជ្រើសរើសសហគ្រិននារីឆ្នើម
១៣-ផលិតខ្សែភាពយន្តខ្លី២រឿងដើម្បីលើកស្ទួយផ្សព្វផ្សាយដល់សហគ្រិននារីក្នុងគម្រោង
១៤-សម្របសម្រួលកិច្ចប្រជុំជាទៀងទាត់ជាមួយដៃគូរអនុវត្តគម្រោងបិតក្រោមក្របខណ្ឌគម្រោង WE Act
១៥-បង្កើត Website ដើម្បីជួយផ្សព្វផ្សាយលើកស្ទួយពីកិច្ចការបណ្តាញសហគ្រិននារីវ័យក្មេង និងសមាជិកបណ្តាញ
១៦-រៀបចំវេទិកាសិក្សារៀនសូត្ររបស់សហគ្រិននារីវ័យក្មេងប្រចាំត្រីមាស
១៧-ផ្តល់សម្ភារៈបរិក្ខាគាំទ្រដល់បណ្តាញសហគ្រិននារីវ័យក្មេងប្រតិបត្តិការការងារ
១៨-កសាងសមត្ថភាពដល់គណៈកម្មការបណ្តាញសហគ្រិននារី និងកសាងផែនការយុទ្ធសាស្ត្រ

<u>គម្រោងទី២៖</u>

មិនមានផែនការដោយសារម្ចាស់គម្រោងបានដកគម្រោង WeEffect ចេញពីកម្ពុជានៅឆ្នាំ២០២០

<u>ខេត្តឧត្តរមានជ័យ</u>

**លទ្ធផលរំពឹងទុកទី១៖ សាលាចំនួន២៥ បានបញ្ចូលមុខវិជ្ជាបំណិនជីវិតទៅក្នុងកម្មវិធីសិក្សា ដោយមានម៉ោងសិក្សាអំពីមេរៀនបំណិនជីវិតច្បាស់លាស់ ព្រមទាំងមានការជំរុញការអនុវត្តកម្មវិធីបំណិនជីវិតតាមសាលាទាំងនោះបានយ៉ាងល្អ ប្រសើរ។**

១-បើកវគ្គបណ្តុះបណ្តាលពីបំណិនជីវិតរបស់ក្រសួងអប់រំដល់ មន្ទីរអប់រំ ការិយាល័យអប់រំក្រុងស្រុក នាយកម្រង និងនាយកសាលាគោលដៅចំនួន២៥សាលាបឋមសិក្សា

២-បើគាំទ្រសាលាគោលដៅចំនួន២៥ផែនការអភិវឌ្ឍន៍សាលារៀនក្នុងការអនុវត្តសកម្មភាពបំណិនជីវិត

៣-បើត្រួតពិនិត្យតាមដានការអនុវត្តសកម្មភាពបំណិនជីវិតនិងផែនការអភិវឌ្ឍសាលារៀនរបស់គណៈកម្មការ ទ្រទ្រង់សាលា

៤-ប្រជុំប្រចាំត្រីមាសជាមួយក្លិបដើម្បីអោយក្មេងចេះរៀបចំផែនការ និងអនុវត្តផែនការរបស់ក្លិប

**លទ្ធផលរំពឹងទុកទី២៖ សមាជិកសហគមន៍ចំនួន០៣ (សហគមន៍ព្រៃឈើរំដួលវាសនា សហគមន៍ព្រៃឈើ សំរ៉ែកព្រៃស្រស់ និងសហគមន៍ព្រៃឈើរត្តនរុក្ខា និងបណ្តាញសហគមន៍ព្រៃឈើ) យ៉ាងតិច៧០% ក្នុងចំណោម សមាជិកសហគមន៍ព្រៃឈើសរុប៤២៦នាក់ និងស្ត្រី១៨៥នាក់ និងបណ្តាញសហគមន៍ចំនួន១២នាក់ មានស្ត្រីម្នាក់ បានយល់ច្បាស់អំពីការបង្កើតសហគមន៍ព្រៃឈើ អត្ថប្រយោជន៍នៃការបង្កើតសហគមន៍ព្រៃឈើ ព្រំប្រទល់ព្រៃសហគមន៍ ព្រមទាំងបានចូលរួមក្នុងសកម្មភាពការពារ និងគ្រប់គ្រងព្រៃសហគមន៍របស់ពួកគាត់។**

១-ប្រជុំនិងអនុវត្តផែនការប្រចាំត្រីមាសដើម្បីពង្រឹងការគ្រប់គ្រងសហគមន៍របស់គណៈកម្មការគ្រប់គ្រង ព្រៃសហគមន៍ទាំង០៣ និងបណ្តាញសហគមន៍ព្រៃឈើទាំង១២

២-គាំទ្រលើផែនការសហគមន៍រតនរុក្ខា រំដួលវាសនា និងសហគមន៍ភ្នំដងរ៉ែកសម្រែកព្រៃស្រស់ និងបណ្តាញ សហគមន៍ព្រៃឈើទាំង១៣

៣-ចូលរួមនិងគាំទ្រក្នុង ការបង្កើតសហគមន៍ទេសចរណ៍ធម្មជាតិនៅក្នុងសហគមន៍ភ្នំដងរ៉ែកសម្រែកព្រៃស្រស់

៤-គាំទ្រគណៈកម្មការគ្រប់គ្រងព្រៃសហគមន៍ចូលរួមក្នុងកម្មវិធីអភិវឌ្ឍន៍ឃុំ-សង្កាត់ និងផែនការវិនិយោគឃុំ-សង្កាត់ប្រចាំឆ្នាំ

៥-សកម្មភាពការត្រៀមបម្រុងសម្រាប់ការងារគ្រប់គ្រងគ្រោះមហន្តរាយ ឬ ឆ្លើយតបគ្រោះមហន្តរាយនៅខេត្តឧត្តរ មានជ័យ។

៦-ចូលរួមសិក្ខាសាលាភាពជាដៃគូប្រចាំឆ្នាំ និងប្រជុំឆមាសនាយកដៃគូជាមួយAAC

៧-ប្រជុំក្រុមប្រឹក្សាភិបាលប្រចាំឆ្នាំ

៨-ត្រួតពិនិត្យនិងឆ្លុះបញ្ចាំងការអនុវត្តសកម្មភាពប្រចាំឆមាស និងរៀបចំ ត្រួតពិនិត្យផែនការឆ្នាំ២០២២

១-បង្ហាញគម្រោងប្រចាំឆ្នាំដល់អ្នកពាក់ព័ន្ធ

**លទ្ធផលរំពឹងទុកទី៣៖ កុមារចំនួន១,០៦៩នាក់/កុមារី៥៩១នាក់ ស្ថិតនៅសង្កាត់ សំរោង បន្សាយរាក់ និងឃុំគោកខ្ពស់អាចទទួលបានការគាំទ្រ និងអត្ថប្រយោជន៍ពីកម្មវិធីអភិវឌ្ឍសហគមន៍ តាមរយៈ ការគូរសារ កម្មវិធី សប្បាយៗ ក្លឹបកុមារ និងការលើក កំពស់សិទ្ធិក្នុងសាលារៀន។**

១-សិក្ខាសាលាកម្មវិធីកុមារ

២-ប្រជុំគ្រូបង្គោល១ឆ្នាំ២ម្តងសម្របសម្រួលលើកម្មវិធីគូសារ

៣-ទិញសម្ភារៈកុមារសម្រាប់កុមារគូសារ

៤-ជួប ថតរូបកុមារ និង Uploud ចូលប្រព័ន្ធAAC

៥-ការអប់រំក្មេងទូទៅ និងប្រមូលសារ១ឆ្នាំ២ម្តង

៦-កម្មវិធីសប្បាយៗតាមក្លឹប(បញ្ញាបកម្មវិធីកុមារ)ធ្វើការអប់រំនិងក្មេងពីអនាម័យខ្លួនប្រាណ ចំណីអាហារ និងសំលៀកបំពាក់ ពន្យល់ពីសារៈប្រយោជន៍នៃការចូលរួមគូរ គំនូ ធ្វើការរំលឹកឡើងវិញពីសិទ្ធិកុមារទាំង១០

សៀមរាបថ្ងៃទី............ខែ..................... ឆ្នាំ២០២១

រៀបចំរបាយការណ៍ដោយ

**នាយកប្រតិបត្តិ**

បានឃើញនិងពិនិត្យ

**ប្រធានក្រុមប្រឹក្សាភិបាល** ............................

..................................




ពិធីផ្តល់សម្ភារៈថែរក្សាអនាម័យមាន ឧបករណ៍វាស់កម្តៅ ម៉ាស់ អាល់កុល សាប៊ូលាងដៃ ដើម្បីការពារ បង្ការការឆ្លងរីករាលដាលជំងឺCOVID-19 ក្នុងកំឡុងពេលដំណើរការបើកសាលារៀនឡើងវិញ ដល់សាលាបឋមសិក្សា៥កម្រង ២៦សាលានៃគោលដៅគម្រោង LRP នៅខេត្តឧត្តរមានជ័យ



វគ្គបណ្តុះបណ្តាលកម្មវិធីពន្លកអាជីវកម្មចំនួន៥វគ្គដល់សហគ្រិននារីយ៉ក្មេងនិងយុវជន៥៤នាក់ ក្នុងខេត្តសៀមរាប



ការផ្តល់អំណាយស្បៀងសង្គ្រោះដល់គ្រួសារក្រីក្ររងផលប៉ះពាល់ជីវភាពក្នុងកំឡុងពេលជួបវិបត្តិជំងឺកូវីត១៩ ២៥០គ្រួសារនៅខេត្តឧត្តរមានជ័យ


ការចុះអប់រំផ្សព្វផ្សាយពីវិធានការការពារទប់ស្កាត់ការរីករាលដាលជំងឺកូវីត១៩ដល់ភូមិគោលដៅគម្រោងទាំង៣៥ក្នុងខេត្តឧត្តរមានជ័យ



វគ្គបណ្តុះបណ្តាលកម្មវិធីពន្លឿនអាជីវកម្មចំនួន៥វគ្គដល់សហគ្រិននារីវ័យក្មេងនិងយុវជន៤៥នាក់ ក្នុងខេត្តសៀមរាប



ពិធីបិទវគ្គចែកវិញ្ញាបនប័ត្របញ្ចប់វគ្គបណ្តុះបណ្តាលដល់សហគ្រិននារីវ័យក្មេងក្នុងគម្រោងខេត្តសៀមរាប